

របាយការណ៍វឌ្ឍនភាព និងសមិទ្ធផល
ស្តីពីការឆ្លើយតបទូលំទូលាយ និងពហុវិស័យ
ទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍

ប្រចាំឆមាសទី១ ឆ្នាំ២០១៨

រៀបរៀងដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ខែភទ្របទ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
ខែកញ្ញា ឆ្នាំ២០១៨

សេចក្តីថ្លែងអំណរគុណ

ជាបឋមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍទាំងអស់ដែលបានផ្តល់នូវទិន្នន័យ ព័ត៌មាន និងរបាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ ទាន់ពេលវេលាដែលអាចឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រើប្រាស់ក្នុងការរៀបចំចងក្រងជារបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានគ្រប់ជ្រុងជ្រោយទូលំទូលាយ និងពហុវិស័យប្រចាំឆមាសទី១ ឆ្នាំ២០១៨ ទោះបីមានការយឺតយ៉ាវ និងមិនទាន់បានគ្រប់ស្ថាប័នទាំងអស់ ក៏របាយការណ៍នាពេលនេះកាន់តែមានភាពប្រសើរជាងមុន។

សូមសំដែងនូវការកោតសរសើរផងដែរជូនចំពោះ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលបានដឹកនាំ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់លើការងាររៀបចំរបាយការណ៍នេះ ជាពិសេសនាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ និងក្រុមការងារទាំងអស់ដែលបានខិតខំយ៉ាងសកម្មក្នុង ការប្រមូល សម្អាត ផ្ទៀងផ្ទាត់ វិភាគទិន្នន័យ និងចងក្រងនូវព័ត៌មានទាំងអស់ដែលទាក់ទងនឹងវឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាឱ្យមានរូបរាងឡើងជារបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ ប្រកបដោយភាពជោគជ័យ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍នេះពិតជាឆ្លុះបញ្ចាំងនូវការពិតស្តីពីបច្ចុប្បន្នភាពនៃការឆ្លើយតបជាតិទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងអាចយកទៅប្រើប្រាស់ក្នុងការសម្រេចចិត្តលើកកម្ពស់ ការអនុវត្តផែនការសកម្មភាពជាតិជាបន្តឱ្យបានកាន់តែប្រសើរថែមទៀតនៅក្នុងចំណោមស្ថាប័នជាតិ អន្តរជាតិ ស្ថាប័នសង្គមស៊ីវិល ដៃគូអភិវឌ្ឍ ស្ថាប័នឯកជន។ល។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ..... ឆ្នាំ២០១៨

ទេសរដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ម៉ូលី

មាតិកា

សេចក្តីថ្លែងអំណរគុណ.....i

ពាក្យកាត់ និងពាក្យបំព្រួញ.....iv

បញ្ជីតារាង.....v

បញ្ជីរូបភាព.....vi

១. សេចក្តីផ្តើម.....១

១.១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍.....១

១.២ គម្រោងផែនការសកម្មភាពជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅឆ្នាំ២០១៨.....១

២. គោលបំណង និងកម្មវត្ថុ.....២

២.១ គោលបំណង.....២

២.២ កម្មវត្ថុ.....២

៣. វិធីសាស្ត្រ.....៣

៤. លទ្ធផល.....៤

៤.១ ក្រសួង ស្ថាប័នដែលបានផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ.....៤

៤.២ រាជធានី ខេត្តដែលបានផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ.....៤

៤.៣ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី១ "ផ្តួចផ្តើមការបង្ការមេរោគអេដស៍ដោយផ្តោតលើអន្តរាគមន៍ដែលបង្កើនការគ្របដណ្តប់ដែលមានគុណភាព និងប្រសិទ្ធភាពនៃអន្តរាគមន៍បង្ការ ៥

៤.៣.១ ការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍.....៥

៤.៣.២ ការចែកចាយ និងលក់ស្រោមអនាម័យ.....១០

៤.៣.៣ សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ អប់រំផ្សព្វផ្សាយពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងសុខភាពបន្តពូជ.....១០

៤.៤ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី២: បង្កើននិងរក្សាគុណភាពការគ្របដណ្តប់ និងការរក្សាទុកគ្រប់ជំហានទាំងអស់នៅក្នុងការថែទាំព្យាបាលបន្តដោយយកភ័ស្តុតាង និងការណែនាំជាមូលដ្ឋាន.....១៦

៤.៤.១ អតិថិជនមកទទួលសេវាផ្តល់ការប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់.....១៦

៤.៤.២ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន.....១៧

៤.៤.៣ សមិទ្ធផលនៃការផ្តល់សេវា.....១៩

៤.៤.៣.១ សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍.....១៩

៤.៥ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៣: កាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការបង្កើនការគ្របដណ្តប់អន្តរាគមន៍ដែលមានគុណភាព និងប្រសិទ្ធភាព.....២២

៤.៦ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៤: ការដឹកនាំសម្របសម្រួលភាគីពាក់ព័ន្ធការពារគរ និងបែងចែកធនធាន(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទាំង៥ទៀត).....២៣

៤.៦.១ ការងារដឹកនាំ គ្រប់គ្រង សម្របសម្រួលការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ ជំងឺអេដស៍ (១).....២៣

៤.៧ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៥: បង្កនិងបង្កើតបរិស្ថានការគាំទ្រតាមរយៈការយល់ដឹងនិងការអនុវត្តច្បាប់និងគោលនយោបាយឱ្យកាន់តែប្រសើរឡើង".....២៤

៤.៨ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៦: បង្កើនប្រព័ន្ធតាមដាននិងវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តែមួយ(ទាំងក្នុងវិស័យសុខភាពនិងវិស័យដទៃទៀត)(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទាំង៥ទៀត).....២៥

៤.៨.១ គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ.....២៥

៤.៨.២ ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព.....២៥

៤.៨.៣ ការគ្រប់គ្រងទិន្នន័យ.....២៦

៤.៨.៤ ការផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មាន.....២៦

៤.៨.៥ ពង្រឹងការត្រួតពិនិត្យការចំណាយថវិកាទៅលើជំងឺអេដស៍.....២៧

៥. ដែនកំណត់.....២៨

៦. សេចក្តីសន្និដ្ឋាន:.....៣០

៧. អនុសាសន៍:.....៣២

ឯកសារយោង:.....៣៤

ឧបសម្ព័ន្ធ.....៣៧

ពាក្យកាត់ និងពាក្យបំព្រួញ

អ ជ ប ជ អ	អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
AIDS	Acquired Immune Deficiency Syndrome (ជំងឺអេដស៍)
AHF	AIDS Healthcare Foundaion (មូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍)
ARV	Anti-Retroviral (ឱសថប្រឆាំងនឹងមេរោគអេដស៍)
ART	Anti-Retroviral Therapy (ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍)
AUA	Association of ARV User (សមាគមន៍អ្នកប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍)
BC	(បណ្តាញចតុមុខ)
CCC	Country Coordinating Committee (គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំប្រទេសកម្ពុជា)
CNPUD	Cambodia Network for People Using Drug
CPN+	Cambodia Network of People Living with HIV/AIDS (បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា)
CWPD	Cambodian Women for Peace and Development (សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
EW	Entertainment Worker (អ្នកបម្រើសេវាកម្សាន្តសប្បាយ)
GARPR	Global AIDS Response Progress Reporting (របាយការណ៍វឌ្ឍនភាពចូលរួមឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាសកល)
HACC	Health Action Coordination committee (គណៈកម្មការសម្របសម្រួលសកម្មភាពសុខភាព)
HIV	Human Immunodeficiency Virus (មេរោគអេដស៍)
KAP	Knowledge Attitude Pratice (ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត)
KORSANG	អង្គការកសាង
MSM	Men who have Sex with Men (បុរសស្រឡាញ់បុរស)
NAA	National AIDS Authority (អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍)
NASA	National AIDS Spending Assessment (ការអង្កេតស្តីពីការចំណាយជាតិប្រយុទ្ធនឹងជំងឺអេដស៍)
NEWN	National Entertainment Worker Network (បណ្តាញអ្នកបម្រើសេវាកម្សាន្តសប្បាយ)
PLHIV	People Living With HIV (អ្នកផ្ទុកមេរោគអេដស៍)
PWID	People Who Inject Drugs (អ្នកចាក់គ្រឿងញៀន)
PWUD	People Who Use Drugs (អ្នកប្រើគ្រឿងញៀន)
TG	Transgender (ក្រុមបំលែងភេទ)
UNAIDS	United Nations Joint Program on AIDS (កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍របស់អង្គការសហប្រជាជាតិ)
VCCT	Voluntary Confidential Counselling and Testing (ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់)
WNU	Women Network for Unity (បណ្តាញការងារស្ត្រីរួបរួមគ្នា)

បញ្ជីតារាង

១. តារាងទី១: សមិទ្ធផលនៃការផ្តល់ទិន្នន័យពីក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.ជ.អ.....៤

២. តារាងទី២: សមិទ្ធផលនៃការផ្តល់ទិន្នន័យពីរាជធានី ខេត្តជាសមាជិក អ.ជ.ប.ជ.អ.....៤

៣. តារាងទី៣: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយក្នុងរាជធានី ខេត្តទាំង២២.....៥

៤. តារាងទី៤: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមបុរសស្រឡាញ់បុរសក្នុងរាជធានី ខេត្តទាំង២២ .....៦

៥. តារាងទី៥: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមអ្នកប្រើប្រាស់គ្រឿងញៀនក្នុងខេត្តចំនួន៣.....៦

៦. តារាងទី៦: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមប្រជាជនចល័តក្នុងខេត្តចំនួន១.....៦

៧. តារាងទី៧: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមប្រជាជនចល័តក្រៅខេត្តចំនួន១.....៧

៨. តារាងទី៨: សមិទ្ធផលនៃការចុះអប់រំដល់ក្រុមឯកសណ្ឋានក្នុងខេត្តចំនួន៧.....៧

៩. តារាងទី៩: សមិទ្ធផលនៃការអប់រំដល់ក្រុមយុវវ័យក្នុងសាលាក្នុងខេត្តចំនួន១២.. .....៨

១០.តារាងទី១០: សមិទ្ធផលនៃការអប់រំដល់ក្រុមយុវវ័យក្រៅសាលាក្នុងខេត្តចំនួន ៨

១១. តារាងទី១១: សមិទ្ធផលនៃការអប់រំដល់ក្រុមទណ្ឌិតក្នុងខេត្តចំនួន១១.....៩

១២.តារាងទី១២: របាយការណ៍ចំនួនពលករដែលបានទទួលការអប់រំ និងផ្សព្វផ្សាយពីជំងឺអេដស៍.....១២

១៣.តារាងទី១៣: ចំនួនប្រជាជនដែលបានទទួលសេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ក្នុងខេត្តចំនួន២១.....១៦

១៤.តារាងទី១៤: ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យថែទាំផ្ទៃពោះលើកដំបូងដោយបែងចែកទៅតាមការប្រើប្រាស់សេវា.....១៦

១៥.តារាងទី១៥: ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យផ្ទៃពោះលើកដំបូងដោយបែងចែកទៅតាមប្រភេទក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍.....១៧

១៦.តារាងទី១៦: អត្រាស្ត្រីមានផ្ទៃពោះដែលទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់.....១៧

១៧.តារាងទី១៧: អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលលទ្ធផលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់.....១៧

១៨.តារាងទី១៨: អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តរកមេរោគអេដស៍...១៨

១៩.តារាងទី១៩: លទ្ធផលនៃស្ត្រីមានផ្ទៃពោះដែលទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ១៨

២០.តារាងទី២០: សមិទ្ធផលនៃកុមារងាយរងគ្រោះដោយសារជំងឺអេដស៍បានទទួលការគាំទ្រពីសង្គមក្នុងខេត្តចំនួន.....២១

បញ្ជីរូបភាព

១. រូបភាពទី១: និន្នាការចំនួនទីកន្លែង និងអ្នកផ្តុំកមេរោគអេដស៍ដែលផ្តល់ និងទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ២០០១ ដល់ត្រីមាសទី៤ ឆ្នាំ ២០១៧.....២០

២. រូបភាពទី២: និន្នាការអ្នកផ្តុំកមេរោគអេដស៍កុមារ និងមនុស្សពេញវ័យដែលបានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ២០១៣ ដល់ត្រីមាសទី៤ ឆ្នាំ ២០១៧.....២០

១. សេចក្តីផ្តើម

១.១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានបេសកកម្មរបស់ខ្លួនក្នុងការដឹកនាំគ្រប់គ្រង និងសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាយោងទៅតាម: ១) គម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ (២០១៥-២០២០) ២) គម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០១៨ ៣) ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ គោលនយោបាយប្រាំពីរចំណុចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ តាមលិខិតលេខ២០៤៨ ស.ជ.ណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងសេចក្តីសម្រេចចិត្តនានានៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៤) សេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិក្នុងយុទ្ធសាស្ត្រសូន្យបីដោយប្រកាន់នូវគោលការណ៍បី-មួយ និងគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០ និង ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ ក្នុងការ គាំទ្រដល់ការឆ្លើយតបទូលំទូលាយ និងពហុវិស័យតាមរយៈការប្រើប្រាស់រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង និងសម្របសម្រួលជាតិតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាតិតែមួយ។

១.២ គម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៨

យោងតាមព័ត៌មានដែលទទួលបានពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៨ កន្លងមក គម្លាតនៃការឆ្លើយតប និងអនុសាសន៍ដែលមានលក្ខណៈអនុវត្តជាក់ស្តែងបានយកមកប្រើប្រាស់ក្នុងការរៀបចំជាផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៨ ដោយប្រើប្រាស់យុទ្ធសាស្ត្រជាតិទាំង៦ ជាគោលដូចខាងក្រោម:

១.២.១. យុទ្ធសាស្ត្រទី១: ការបង្ការការចម្លងមេរោគអេដស៍ថ្មី

១.២.២. យុទ្ធសាស្ត្រទី២: ការព្យាបាល ថែទាំ និងគាំទ្រអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍

១.២.៣. យុទ្ធសាស្ត្រទី៣: ការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍

១.២.៤. យុទ្ធសាស្ត្រទី៤: ការបង្កើនភាពជាអ្នកដឹកនាំ គ្រប់គ្រង និងចលនាធនធាន

១.២.៥. យុទ្ធសាស្ត្រទី៥: ការបង្កើតបរិយាកាសគាំទ្រ និងគោលនយោបាយ

១.២.៦. យុទ្ធសាស្ត្រទី៦: ការតាមដាន វាយតម្លៃ និងប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រ

២. គោលបំណង និងកម្មវត្ថុ

២.១ គោលបំណង

ចងក្រង និងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០១៨ និងដើម្បីប្រើប្រាស់ជាឯកសារក្នុងការវាយតម្លៃពីវឌ្ឍនភាព នៃការអនុវត្តគម្រោងផែនការសកម្មភាពប្រចាំឆមាសទី១ ឆ្នាំ២០១៨ ផងដែរ។ លើសពីនេះ របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០១៨នេះ នឹងប្រើប្រាស់ជាឯកសារយោងក្នុងការកែលំអការរៀបចំផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆមាសទី២ ឆ្នាំ២០១៨ ឱ្យកាន់តែប្រសើរថែមទៀត។

២.២ កម្មវត្ថុ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ ការរៀបចំរបាយការណ៍នេះមានកម្មវត្ថុមួយចំនួនដូចខាងក្រោម:

២.២.១ ប្រមូល សម្អាត និងវិភាគទិន្នន័យដែលប្រមូលបានពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាតិឱ្យក្លាយទៅជាព័ត៌មានវិទ្យាសាស្ត្រពិត និងប្រកបដោយទំនុកចិត្តខ្ពស់។

២.២.២ រៀបចំព័ត៌មានឱ្យទៅជាតារាង ឬរូបភាពដោយមានការបកស្រាយច្បាស់លាស់ពី ខ្លឹមសាររបស់វាឱ្យបានត្រឹមត្រូវ។

២.២.៣ រៀបចំការសម្របសម្រួល និងស្វែងរកការឯកភាពរួមគ្នារវាងស្ថាប័ន និងបុគ្គលទាំងអស់ដែលទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ទៅលើព័ត៌មានដែលបានបកស្រាយនៅក្នុងរបាយការណ៍នេះ។

៣. វិធីសាស្ត្រ

របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលឆមាសទី១ ឆ្នាំ២០១៨នេះ គឺបានរៀបចំឡើងដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយប្រើប្រាស់នូវទម្រង់ប្រមូលទិន្នន័យជាតិ និងប្រព័ន្ធត្រួតពិនិត្យជាតិមួយដែលចាប់យកនូវទិន្នន័យទាំងអស់ពីការអនុវត្តផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាលនៅទូទាំងប្រទេសដែលបានផ្ញើមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅរៀងរាល់សប្តាហ៍ទី២ ក្រោយឆមាសនីមួយៗ។

បន្ទាប់ពីទទួលបាននូវទិន្នន័យជាតិរួចហើយ វិធីសាស្ត្រគ្រប់គ្រងទិន្នន័យ បានប្រើប្រាស់ក្នុងការសម្អាត ផ្ទៀតផ្ទាត់ និងវិភាគទិន្នន័យបន្តដោយវិធីសាស្ត្ររៀបចំព័ត៌មានឱ្យទៅជាតារាង ឬរូបភាព និងបញ្ចប់ដោយការបកស្រាយ។ វិធីសាស្ត្រដែលប្រើប្រាស់ចុងក្រោយបង្អស់គឺវិធីសាស្ត្រចងក្រងរបាយការណ៍ដោយរៀបចំការសរសេរជាសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨។

បន្ទាប់ពីបានរៀបចំនូវសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលក្នុងការឆ្លើយតបទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ ចប់សព្វគ្រប់ហើយ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវបានផ្ញើជូននាយកដ្ឋានទាំងអស់របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្តល់យោបល់កែលំអ បន្ទាប់មកសេចក្តីព្រាងរបាយការណ៍នេះក៏បានយកមករៀបចំកែសម្រួលទៅតាមការផ្តល់យោបល់ឱ្យទៅជា សេចក្តីព្រាងរបាយការណ៍លើកទី២ ដើម្បីដាក់ជូនទៅសុំមតិយោបល់បន្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងគោលបំណងបំពេញបន្ថែមនូវគម្លាត ព័ត៌មាន និងដើម្បីកែសម្រួលរាល់ចំណុចខ្វះខាតនានាពាក់ព័ន្ធជាសំខាន់ទៅលើសុក្រឹតភាព និងជំនឿទុកចិត្តទៅលើព័ត៌មានទាំងនោះ។

លទ្ធផលដែលប្រមូលបានពីការពិគ្រោះយោបល់នៅក្នុង កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានយកមកប្រើប្រាស់ក្នុងការរៀបចំបញ្ចប់របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលក្នុងការឆ្លើយតបទូលំទូលាយ និងពហុវិស័យការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ ដើម្បីដាក់ជូនថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីសម្រេចនិងធ្វើការផ្សព្វផ្សាយជូនដល់សមាជិក សមាជិកា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤. លទ្ធផល

ជារួមនៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទទួលបានទិន្នន័យពីក្រសួងចំនួន១៨ក្នុងចំណោមក្រសួង ស្ថាប័នសរុបចំនួន២៦។ (តារាងទី១) (ឧបសម្ព័ន១)។

៤.១ ក្រសួង ស្ថាប័នដែលបានផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

តារាងទី១: សមិទ្ធផលនៃការផ្តល់ទិន្នន័យពីក្រសួង ស្ថាប័នជាសមាជិកអ.ជ.ប.ជ.អ

សូចនាករ	ចំនួនក្រសួង ស្ថាប័នដែលបានផ្តល់ទិន្នន័យ	ចំនួនក្រសួង ស្ថាប័នសមាជិក អ.ជ.ប.ជ.អ	សមិទ្ធផល (%)
ចំនួន (#) ក្រសួង ស្ថាប័នដែលផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ	១៨	២៦	៦៩.២៣

ដោយឡែកមានរាជធានី ខេត្តចំនួន២២ ដែលបានផ្ញើទិន្នន័យប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ មកកាន់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ (តារាងទី២) (ឧបសម្ព័ន្ធ១) ។

៤.២ រាជធានី ខេត្តដែលផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

តារាងទី២: សមិទ្ធផលនៃការផ្តល់ទិន្នន័យពីរាជធានី ខេត្តជាសមាជិក អ.ជ.ប.ជ.អ

សូចនាករ	ចំនួនរាជធានីខេត្តដែលបានផ្តល់ទិន្នន័យ	ចំនួនរាជធានីខេត្តសមាជិក អ.ជ.ប.ជ.អ	សមិទ្ធផល (%)
ចំនួន (#) រាជធានី ខេត្តដែលផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ	២២	២៥	៨៨.០០

ចំពោះដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ គឺមានចំនួនតែ ៥ ស្ថាប័នប៉ុណ្ណោះដែលបានផ្ញើទិន្នន័យប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ មកកាន់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ លើសពីនេះទៅទៀត គឺគ្មានស្ថាប័នឯកជនណាមួយដែលបានផ្ញើទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឡើយ។

៤.៣ ទស្សនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី១: ផ្តួចផ្តើមការបង្ការមេរោគអេដស៍ ដោយផ្តោតលើអន្តរាគមន៍ ដែលបង្កើនការគ្របដណ្តប់ដែលមានគុណភាព និងប្រសិទ្ធភាព

៤.៣.១ ការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍

ទាក់ទងនឹងការអប់រំមេរោគអេដស៍ និងជំងឺអេដស៍ មានវិធីសាស្ត្រជាច្រើនដែលបានប្រើប្រាស់យោងទៅតាមក្រុមគោលដៅ។ ឧទាហរណ៍: ចំពោះក្រុមគោលដៅប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍ ដូចជាបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយ ក្រុមបុរសស្រឡាញ់បុរស ក្រុមបំលែងភេទ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន វិធីសាស្ត្រចុះអប់រំផ្ទាល់បានយកមកប្រើប្រាស់។ ចំពោះក្រុមប្រឈមផ្សេងទៀតដូចជាក្រុមឯកសណ្ឋាន នគរបាល យោធិន យុវវ័យ និងប្រជាជនទូទៅ វិធីសាស្ត្រអប់រំភាគច្រើនធ្វើឡើងតាមរយៈវេទិកាសាធារណៈ ការបញ្ជ្រាបទៅក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ និងការចុះអប់រំផ្ទាល់តាមសាលារៀន តាមរយៈការបញ្ជ្រាបការអប់រំទៅក្នុងកម្មវិធីសិក្សាបំណិនជីវិត និងមិត្តអប់រំមិត្ត។

ក. បុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយ

តាមទិន្នន័យដែលអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានទទួលពីរាជធានី ខេត្តចំនួន២២ មានបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយប្រមាណជា ៩៤៣០នាក់ បានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានការជំរុញ និងចែកចាយស្រោមអនាម័យ ឬការបញ្ជូនទៅកាន់សេវាគ្រប់គ្រងជំងឺកាមរោគ និងជំងឺអេដស៍។ល។

បើប្រៀបធៀបទៅនឹងចំនួនបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយ ដែលបានចុះបញ្ជីដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ដែលមាននៅក្នុងខេត្តទាំង២២នោះវិញ (៣៤៣៧២នាក់)គឺកម្មវិធីអប់រំមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមគោលដៅជាបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយអាចគ្របដណ្តប់បានត្រឹមតែ ២៧.៤៤%។(តារាងទី៣) (ឧបសម្ព័ន្ធ២)។

តារាងទី៣: សមិទ្ធផលនៃការចុះអប់រំផ្ទាល់ដល់ក្រុមបុគ្គលិកគ្រឹះស្ថានកម្សាន្ត សប្បាយក្នុងរាជធានី ខេត្តទាំង២២ដែលបានផ្តល់ទិន្នន័យ

សូចនាករ	ចំនួនបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយដែល ប្លាន ទទួលការអប់រំ	ចំនួនបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយគោលដៅ	សមិទ្ធផល (%)
ចំនួន(#)បុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍និងជំងឺអេដស៍	៩៤៣០	៣៤៣៧២	២៧.៤៤

ខ. ក្រុមបុរសស្រឡាញ់បុរស

ជាលទ្ធផលក្រុមបុរសស្រឡាញ់បុរសប្រមាណជា ២៨៦៥ នាក់បានទទួលការអប់រំមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានការជំរុញ និងចែកចាយស្រោមអនាម័យ ឬការបញ្ជូនទៅកាន់សេវាគ្រប់គ្រងជំងឺកាមរោគ និងជំងឺអេដស៍។ល។

បើប្រៀបធៀបទៅនឹងចំនួនក្រុមបុរសស្រឡាញ់បុរស ដែលបានចុះបញ្ជីដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដែលមាននៅក្នុងរាជធានី ខេត្តទាំង ១០ នោះវិញមាន ១៦២៣១នាក់ ក្នុងនោះមានខេត្តចំនួន៤ ដែលបានផ្តល់ការអប់រំទៅលើក្រុមគោលដៅជាបុរសស្រឡាញ់បុរសបានចំនួន២៨៦៥ ស្មើនឹង១៧.៦៥% ។ (តារាងទី៤)(ឧបសម្ព័ន្ធ៣)។

តារាងទី៤: សមិទ្ធផលនៃការចុះអប់រំផ្ចាល់ដល់ក្រុមបុរសស្រឡាញ់បុរសក្នុងខេត្តទាំង៤

សូចនាករ	ចំនួនក្រុមបុរសស្រឡាញ់បុរសដែលបានទទួលការអប់រំ	ចំនួនក្រុមបុរសស្រឡាញ់បុរសគោលដៅ	សមិទ្ធផល (%)
ចំនួន(#)ក្រុមបុរសស្រឡាញ់បុរសរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍	២៨៦៥	១៦២៣១	១៧.៦៥

គ. ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន

ក្នុងត្រីមាសទី១ ឆ្នាំ២០១៨ មានរាជធានី ខេត្តចំនួន៩ ដែលបានផ្តល់ទិន្នន័យស្តីពីអ្នកប្រើប្រាស់គ្រឿងញៀនមកអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងនោះមានតែខេត្តចំនួន៣ ប៉ុណ្ណោះ (កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ) ដែលបានផ្តល់ការអប់រំមេរោគអេដស៍ និងជំងឺអេដស៍ដោយមានការជំរុញ និងចែកចាយស្រោមអនាម័យ ឬការបញ្ជូនទៅកាន់សេវាគ្រប់គ្រងជំងឺកាមរោគ... ។ល។ ដល់ក្រុមអ្នកប្រើប្រាស់គ្រឿងញៀនចំនួន ២០៣៣ នាក់ ។ ជាសមិទ្ធផលការអប់រំក្រុមអ្នកប្រើប្រាស់គ្រឿងញៀនអាចសម្រេចបានត្រឹមតែ ៥៨.៦៣%។(តារាងទី៥)(ឧបសម្ព័ន្ធ៤)។

តារាងទី៥: សមិទ្ធផលនៃការចុះអប់រំផ្ចាល់ដល់ក្រុមអ្នកប្រើប្រាស់គ្រឿងញៀនក្នុងខេត្តចំនួន៣

សូចនាករ	ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនដែលបានទទួលការអប់រំ	ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនគោលដៅ	សមិទ្ធផល (%)
ចំនួន (#) បុគ្គលិកក្រុមអ្នកប្រើប្រាស់គ្រឿងញៀនរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍	២០៣៣	៣៤៦៧	៥៨.៦៣

ឃ. ក្រុមប្រជាជនចល័ត

ឃ.១ ក្រុមប្រជាជនចល័តក្នុងស្រុក

យោងតាមទិន្នន័យដែលទទួលបានពីខេត្តចំនួន២ ស្តីពីក្រុមប្រជាជនចល័តក្នុងស្រុកមានដូចជាកម្មកររោងចក្រ កម្មកររនេសាទ កម្មករសំណង់។ល។ គឺមានចំនួនសរុប ១៤៤៨៩នាក់។ ក្នុងនោះមានតែខេត្តព្រៃវែង បានផ្តល់ការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ដល់កម្មកររោងចក្របានចំនួន ១៣២៩១នាក់ ស្មើនឹង៩១.៩៨%។ (តារាងទី៦) (ឧបសម្ព័ន្ធ៥)។

តារាងទី៦: សមិទ្ធផលនៃការចុះអប់រំផ្ដាល់ដល់ក្រុមប្រជាជនចល័តក្នុងខេត្តចំនួន១

សូចនាករ	ចំនួនក្រុមប្រជាជនចល័តដែលបានទទួលការអប់រំ	ចំនួនក្រុមប្រជាជនចល័តគោលដៅ	សមិទ្ធផល (%)
ចំនួន (#) ក្រុមប្រជាជនចល័តរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍និងជំងឺអេដស៍	១៣២៩១១	១៤៤៤៨៩	៩១.៩៨

ឃ.២ ក្រុមប្រជាជនចល័តក្រៅស្រុក

ចំពោះក្រុមគោលដៅជាប្រជាជនចល័តក្រៅស្រុក មានតែខេត្តចំនួន២ ប៉ុណ្ណោះដែលបានផ្ដល់ទិន្នន័យគឺខេត្ត ព្រៃវែង និងកណ្ដាល ដែលមានចំនួនក្រុមគោលដៅសរុប ៥៣៥៣៣នាក់ ក្នុងនោះខេត្តព្រៃវែងបានផ្ដល់ការអប់រំស្ដីពីមេរោគអេដស៍ និងជំងឺអេដស៍ដល់ក្រុមប្រជាជនចំណាកក្រៅស្រុកក្នុងខេត្តរបស់ខ្លួនចំនួន៤៨៩២៦នាក់ ស្មើនឹង៩១.៣៩%។(តារាងទី៧)។

តារាងទី៧: សមិទ្ធផលនៃការចុះអប់រំផ្ដាល់ដល់ក្រុមប្រជាជនចល័តក្រៅខេត្តចំនួន១

សូចនាករ	ចំនួនក្រុមប្រជាជនចល័តដែលបានទទួលការអប់រំ	ចំនួនក្រុមប្រជាជនចល័តគោលដៅ	សមិទ្ធផល (%)
ចំនួន (#) ក្រុមប្រជាជនចល័តរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍និងជំងឺអេដស៍	៤៨៩២៦	៥៣៥៣៣	៩១.៣៩

ង. ក្រុមឯកសណ្ឋាន

ក្នុងចំណោម ២២ រាជធានី ខេត្ត ដែលបានផ្ដល់របាយការណ៍ត្រីមាសទី១ គឺមានខេត្តចំនួន១០ប៉ុណ្ណោះដែលបានបំពេញទិន្នន័យពីក្រុមឯកសណ្ឋាន ហើយក្នុងនោះដែរមានតែ ៧ ខេត្តដែលបានធ្វើការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់កងកម្លាំង ប៉ូលិស យោធិន និងក្រុមឯកសណ្ឋានសរុបចំនួន ៤៧៨៦នាក់ ស្មើនឹង ២៥.១២%។ (តារាងទី៨)(ឧបសម្ព័ន្ធ៦)។

តារាងទី៨: សមិទ្ធផលនៃការចុះអប់រំដល់ក្រុមឯកសណ្ឋានក្នុងខេត្តចំនួន៧

សូចនាករ	ចំនួនក្រុមឯកសណ្ឋានដែលបានទទួលការអប់រំ	ចំនួនក្រុមឯកសណ្ឋានគោលដៅ	សមិទ្ធផល (%)
ចំនួន (#) ក្រុមឯកសណ្ឋានរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍	៤៧៨៦	១៩០៤៥	២៥.១២

ច. ក្រុមយុវវ័យក្នុងសាលា និងក្រៅសាលា

ច.១ ក្រុមយុវវ័យក្នុងសាលា

យោងតាមទិន្នន័យពីរាជធានី ខេត្ត ចំនួន ២២ មានតែ ១២ ខេត្ត ដែលបានផ្តល់ទិន្នន័យពីក្រុមយុវវ័យក្នុងសាលារៀននៅគ្រប់កម្រិត (បឋមសិក្សា មធ្យមសិក្សា) ទាំងអស់សរុបចំនួន ២១៦២៥៩៣នាក់ គឺបានផ្តល់ការអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដែលភាគច្រើនការអប់រំបានបញ្ចូលក្នុងកម្មវិធីសិក្សា ***បំណិនជីវិត*** សរុបចំនួន ៨៤៧៨៩៣នាក់ ទទួលបានអត្រាគ្របដណ្តប់បាន ៣៩.២០ %។(តារាងទី៩)(ឧបសម្ព័ន្ធ៧)។

តារាងទី៩: សមិទ្ធផលនៃការអប់រំដល់ក្រុមយុវវ័យក្នុងសាលាក្នុងខេត្តចំនួន១២

សូចនាករ	ចំនួនក្រុមយុវវ័យក្នុងសាលាបានទទួលការអប់រំ	ចំនួនក្រុមយុវវ័យក្នុងសាលាគោលដៅ	សមិទ្ធផល (%)
ចំនួន (#) ក្រុមយុវវ័យក្នុងសាលារាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍។	៨៤៧៨៩៣	២១៦២៥៩៣	៣៩.២០

ច.២ ក្រុមយុវវ័យក្រៅសាលា

យោងតាមទិន្នន័យដែលទទួលបានពីខេត្តចំនួន២ ក្នុងត្រីមាសទី១ឆ្នាំ២០១៨នេះ បានបង្ហាញឱ្យឃើញថាមានក្រុមយុវវ័យក្រៅសាលារៀនសរុបចំនួន ១៨៣៤៣១នាក់ ហើយក្នុងនោះពុំមានខេត្តណាបានផ្តល់ការអប់រំទេ។ (តារាងទី១០)(ឧបសម្ព័ន្ធ៨)។

តារាងទី១0: សមិទ្ធផលនៃការអប់រំដល់ក្រុមយុវវ័យក្រៅសាលាក្នុងខេត្តចំនួន0

សូចនាករ	ចំនួនក្រុមយុវវ័យក្រៅសាលាដែលទទួលការអប់រំ	ចំនួនក្រុមយុវវ័យក្រៅសាលាគោលដៅ	សមិទ្ធផល (%)
ចំនួន (#) ក្រុមយុវវ័យក្រៅសាលារាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍។	0	១៨៣៤៣១	0

ឆ. ក្រុមទណ្ឌិត

កន្លងមកអន្តរាគមន៍បង្ការទៅលើក្រុមទណ្ឌិតពុំទាន់មានកម្មវិធីទូលំទូលាយ ឬស្ថាប័ន និងអង្គការណាមួយជួយធ្វើបទអន្តរាគមន៍ទៅលើក្រុមនេះនៅឡើយទេ។ ដើម្បីលើកកម្ពស់ការអនុវត្តសកម្មភាពបង្ការ ថែទាំ និងព្យាបាលឱ្យបានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ផែនការយុទ្ធសាស្ត្រជាតិលើកទី៤ បានកំណត់បទអន្តរាគមន៍បង្ការក្នុងចំណោមក្រុមគោលដៅ ត្រូវទទួលបានការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍។ យោងតាមទិន្នន័យដែលទទួលបានពីរាជធានី ខេត្តចំនួន ១៣ មានទិន្នន័យទណ្ឌិតចំនួន ៩២៥១នាក់ ក្នុងនោះមានតែខេត្តចំនួន១១ ទេដែលបានផ្តល់ការអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ដល់ទណ្ឌិតបានចំនួន ៤២៦៧នាក់។ ជាសមិទ្ធផលគឺអាចសម្រេចបាន ៤៦.១២%។ (តារាងទី១១) (ឧបសម្ព័ន្ធ៩)។

តារាងទី១១: សមិទ្ធផលនៃការអប់រំដល់ក្រុមទណ្ឌិតក្នុងខេត្តចំនួន១១

សូចនាករ	ចំនួនក្រុមទណ្ឌិតបានទទួលការអប់រំ	ចំនួនក្រុមទណ្ឌិតគោលដៅ	សមិទ្ធផល (%)
ចំនួន(#) ក្រុមទណ្ឌិតរាជធានី ខេត្តដែលបានទទួលការអប់រំពីមេរោគអេដស៍និងជំងឺអេដស៍។	៤២៦៧	៩២៥១	៤៦.១២

ជ. ក្រុមប្រជាជនចល័ត

ក្នុងឆមាសទី៤ ឆ្នាំ២០១៨នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ មិនបានទទួលរបាយការណ៍ទាក់ទងនិងការផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការស្វែងរកព័ត៌មានស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ជាពិសេសក្នុងចំណោមស្ត្រី និងកុមារីទេ ។

៤.៣.២ ការចែកចាយ និងលក់ស្រោមអនាម័យ

ជាមួយគ្នានេះដែរ ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ អ.ជ.ប.ជ.អ បានរៀបចំពិធីចែកស្រោមអនាម័យចំនួន៥០ម៉ឺនស្រោម ជូនដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត និងអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានទទួលទិន្នន័យដែលទាក់ទងនឹងការចែកចាយស្រោមអនាម័យពីខេត្តចំនួន ១៧ ក្នុងនោះបានចែកចាយស្រោមអនាម័យចំនួន ៥១៧២១២ (ពីអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៥០២៨១២៨ ស្រោមអនាម័យ) និងលក់បានចំនួន ៥៦៥៩២២ស្រោមអនាម័យដោយអង្គការមិនមែនរដ្ឋាភិបាល ។

ការចែកចាយ និងលក់ស្រោមអនាម័យតាមរាជធានី ខេត្ត

យោងតាមរបាយការណ៍ដែលបានទទួលបានពីរាជធានី ខេត្តទាំង២២ ការចែកចាយស្រោមអនាម័យដោយសេវាសាធារណៈបានចំនួន១២៩១៨២ស្រោម និងអង្គការដៃគូសហការតាមរាជធានី ខេត្ត ចែកចាយបានចំនួន ៨០៥៨៦ ស្រោម និងលក់បានចំនួន ៣២២១៨ ស្រោម។

អង្គការ កី អេស អាយ កម្ពុជា

អង្គការ កី អេស អាយ កម្ពុជា បានធ្វើការងារលើកកម្ពស់ទីផ្សារស្រោមអនាម័យ ជំរុញការប្រើប្រាស់ស្រោមអនាម័យ ដោយបានលក់ស្រោមអនាម័យចំនួន ២,៩៧១,៥៤២ ក្នុងរយៈពេល៣ខែ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០១៨។

៤.៣.៣ សកម្មភាពរបស់ដៃគូអភិវឌ្ឍ អប់រំផ្សព្វផ្សាយពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងសុខភាពបន្តពូជ

១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ និងអង្គការដៃគូអភិវឌ្ឍ

- **យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងទិវានៃក្តីស្រឡាញ់**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសហការជាមួយអង្គការសង្គមស៊ីវិល បើកយុទ្ធនាការផ្សព្វផ្សាយអប់រំ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ជូនដល់ប្រជាជនទូទៅ និងយុវជន នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាព**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- **យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសហការជាមួយក្រសួងការពារជាតិ និងអង្គការ AHF បានរៀបចំសិក្ខាសាលាស្តីពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងបញ្ហាប្រឈមរបស់យុវវ័យនៅកម្ពុជា ដល់នាយទាហាន នាយទាហានរង នៅខេត្តកណ្តាល ព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង និងនិស្សិតវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល សរុបទាំងអស់ចំនួន ១២៩០ នាក់។

- **យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមមន្ត្រីរាជការ**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានចូលរួមជាគ្រូឧទ្ទេសលើប្រធានបទ ស្តីពី "ការរីករាលដាលនៃការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍" ក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការប៉ះពាល់នៃគ្រឿងញៀន ទៅលើការរីករាលដាលនៃការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ និងផែនការយុទ្ធសាស្ត្រស្តីពីសិទ្ធជនពិការ" នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- **គោលការណ៍ណែនាំជាតិស្តីពី"ការបង្ការការចម្លងមេរោគអេដស៍ជាសកលនៅតាមគ្រឹះស្ថានមិនមែនសុខាភិបាល "**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសហការជាមួយសមាជិក និងដៃគូការងារបានរៀបចំបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពី "ការបង្ការការចម្លងមេរោគអេដស៍ជាសកលនៅតាមគ្រឹះស្ថានមិនមែនសុខាភិបាល" ។

២. ក្រសួងអប់រំ យុវជន និងកីឡា

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "យុវវ័យ"**

បានបើកវគ្គផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងសុខភាពផ្លូវភេទ គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្រោះថ្នាក់ចរាចរ និងបញ្ហាសង្គមមួយចំនួនទៀត ដល់លោកគ្រូ អ្នកគ្រូ និងសិស្សនៅវិទ្យាល័យ ៣ ក្នុងស្រុកកងមាស ខេត្តកំពង់ចាម មានអ្នកចូលរួម ២១៥៧នាក់ ។

នាយកដ្ឋានយុវជន នៃក្រសួងអប់រំ យុវជន និងកីឡា រៀបចំវគ្គអប់រំពីមេរោគអេដស៍ សុខភាព បន្តពូជ និងគ្រឿងញៀន នៅសាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តព្រះសីហនុ មានអ្នកចូលរួមជាមួយលោកគ្រូ អ្នកគ្រូ គរុសិស្សនិស្សិត និងសិស្សានុសិស្ស សរុប ៤០០នាក់ (ស្រី ១៨៥នាក់) និងនៅសាលាគរុកោសល្យ និងវិក្រិតការខេត្តកំពង់ចាម មានគរុសិស្សចូលរួមសរុប ២០៥នាក់។

៣. ក្រសួងការពារជាតិ

- **ការបញ្ជ្រាបការអប់រំមេរោគអេដស៍ក្នុងកម្មវិធីផ្សេងៗ**

បានបញ្ជ្រាបកម្មវិធីអប់រំបង្ការ ស្តីពីមេរោគអេដស៍ ជំងឺអេដស៍ ក្នុងកម្មវិធីអប់រំចិត្តសាស្ត្រ កម្មវិធីអប់រំជំងឺគ្រុនចាញ់ ព្រមទាំងកម្មវិធីផ្សេងៗទៀត ចំនួន ២៨អង្គភាព នៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ ដែលមានអ្នកចូលរួមសរុប ៩៦៨៧នាក់ (ទ័ព៨៥៧១នាក់ គ្រួសារទ័ព ១១១៦នាក់) ។

- **ការអប់រំមុនធ្វើតេស្តឈាមតាមរយៈរថយន្តចល័ត:**

សហការជាមួយអង្គការ AHF ចុះធ្វើការអប់រំ ផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ តាមរយៈរថយន្តចល័ត បានចំនួន ១៨អង្គភាព មានអ្នកចូលរួមធ្វើតេស្តឈាមសរុប ២១៦៤នាក់ ក្នុងនោះទ័ពមានចំនួន ១៨៨៣នាក់ គ្រួសារទ័ព ៣៤០នាក់ លទ្ធផលតេស្តវិជ្ជមាន ១១នាក់ ស្មើនឹង០.៥១% ។

- **លទ្ធផលពិនិត្យ និងពិគ្រោះជំងឺនៅមន្ទីរពេទ្យយោធភូមិភាគទី៥**

មន្ទីរពេទ្យយោធភូមិភាគទី៥ សហការជាមួយ អង្គការ AHF បានផ្តល់សេវាពិនិត្យ និងពិគ្រោះជំងឺ (សេវាកម្ម ART) ក្នុងរយៈពេល៥ខែ ដើមឆ្នាំ២០១៨ ដោយមានអ្នកមកធ្វើតេស្តឈាម (VCCT) សរុប ១០០០នាក់ (ប្រុស១៩០នាក់ ស្រី ៨១០នាក់) អ្នកបានមកទទួលឱសថ ARV សរុប

៧៩៨នាក់ (ប្រុស ៤៦៩នាក់ ស្រី ៣២៩នាក់) ។ ដោយឡែក អ្នកដែលមកទទួលសេវាព្យាបាលជំងឺឱកាសនិយម (OI) មានចំនួន១៩នាក់ (ប្រុស១៣នាក់ ស្រី ៦នាក់)។

- **លទ្ធផលពិនិត្យ និងពិគ្រោះជំងឺនៅមន្ទីរពេទ្យព្រះកេតុមាលា**

បច្ចុប្បន្នអ្នកដែលមកទទួលការព្យាបាលដោយឱសថ ARV នៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា សរុប ១០៩៧នាក់ ក្នុងនោះប្រុស ៥៦៥នាក់ ស្រី៥៣២នាក់ (ពីឆ្នាំ២០១៣ ដល់បច្ចុប្បន្ន) ។

- **សកម្មភាពរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ**

វគ្គផ្សព្វផ្សាយពីការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងការប្រឈមរបស់យុវវ័យបានចំនួន ៥វគ្គ ចំពោះកងឯកភាព ស្ថាប័ន ចំណុះអគ្គបញ្ជាការដ្ឋាន ដែលមាននាយទាហាន នាយទាហានរង និងពលទាហានចូលរួមសរុបចំនួន ១១៤០ នាក់។

បានអប់រំផ្សព្វផ្សាយពីជំងឺអេដស៍ និងការប្រឈមរបស់យុវវ័យនៅបញ្ជាការដ្ឋានទ័ពជើងទឹក បញ្ជាការមូលដ្ឋានសមុទ្រ សាលាហ្វឹកហ្វឺនឯកទេសបំភ័ន្តអក្ខរៈ ដែលមាននាយទាហាន ពលទាហាន ចូលរួមសរុបចំនួន ១០៨០នាក់ (សហការជាមួយអង្គការ AHF)។

បានបញ្ចូលសកម្មភាពអប់រំ ស្តីពីជំងឺអេដស៍ កាមរោគ គ្រុនចាញ់ គ្រុនឈាម គ្រឿងញៀន គ្រឿងស្រវឹង ក្នុងកម្មវិធីចុះអភិបាលកិច្ច នៅសាលានាយទាហានសកម្ម (ត្បូតពង) បានចំនួន៥ លើក ដែលមានអ្នកចូលរួមសរុបចំនួន ៥២៨នាក់ ។

- **សកម្មភាពរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ**

ធ្វើតេស្តឈាមរកមេរោគអេដស៍បានចំនួន ៣អង្គភាព៖ មូលដ្ឋានសមុទ្រ(រាម) កងពលតូចអន្តរាគមន៍លេខ ១ បញ្ជាការដ្ឋានកងទ័ពជើងអាកាសដែលមានអ្នកធ្វើតេស្តឈាមចំនួន ១០២៤ នាក់ មានតេស្តវិជ្ជមានចំនួន ៣នាក់។

៤. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "ក្រុមប្រជាជនចល័ត"**

អប់រំស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ គ្រឿងញៀន និងសុខភាពបន្តពូជ ដល់ពលករត្រៀមទៅប្រទេសកូរ៉េបានចំនួន ៩៣២នាក់ ។

បានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាស របស់សមាជិកគណៈកម្មការសម្របសម្រួលត្រីភាគីស្តីពីលទ្ធផលការងារ និងទិសដៅអនុវត្តបន្ត។

តារាងទី១២: ព័ត៌មានអំពីចំនួនពលករដែលបានទទួលការអប់រំ និងផ្សព្វផ្សាយពីជំងឺអេដស៍

សកម្មភាព	ចំនួនអ្នកចូលរួម (នាក់)	គិតជា (ស្ត្រី)
វគ្គបណ្តុះបណ្តាលស្តីពីជំងឺអេដស៍ គ្រឿងញៀន និងសុខភាពបន្តពូជ	៩៣២	៣៤៧ នាក់

៥. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "មន្ត្រីរាជការ"**

បានប្រជុំផ្សព្វផ្សាយក្រើនរំលឹកពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល កំពង់ឆ្នាំង កំពង់ចាម និងកំពង់ធំ។

បានចុះផ្សព្វផ្សាយការងារអេដស៍ ដល់សិប្បកម្មផលិតទឹកសុទ្ធក្នុងខេត្តចំនួន ៧ គឺ ពោធិ៍សាត់ បាត់ដំបង សៀមរាប កោះកុង ព្រះសីហនុ មណ្ឌលគិរី និងរតនគិរី។

៦. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "ប្រជាជនទូទៅ"**

បានផ្តល់សារអប់រំពីបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ ដោយប្រើប្រាស់ប្រព័ន្ធលេខទូរស័ព្ទខ្លី៤ខ្ទង់។

One World ដែលបានប្រើលេខ "១២៩៣" សម្រាប់ធ្វើសារអក្សរតាមទូរស័ព្ទដៃជាសំនួរ និងចម្លើយ រវាងប្រជាពលរដ្ឋ និង ក្រុមប្រឹក្សាជំនាញ ក្នុងការអប់រំអំពីបញ្ហាជំងឺអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ។ ពិតមែនតែ One World បានបញ្ចប់បេសកកម្មរបស់ខ្លួនក្តី និរន្តរភាពនៃដំណើរការសារត្រូវបានអង្គការមូលនិធិកុមារកម្ពុជា ជួយសហការបន្តផ្តល់សេវា។

៧. ក្រសួងព័ត៌មាន

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "មន្ត្រីរាជការក្រសួង"**

បានបញ្ជូល និងបញ្ជ្រាបសារអប់រំស្តីពីការបង្ការការចម្លងមេរោគអេដស៍ និងការកាត់បន្ថយការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងសន្និបាតបូកសរុបសមិទ្ធផលវិស័យព័ត៌មាន និងសោតទស្សន៍ ដែលមានសមាជិកចូលរួមចំនួន ៤០០នាក់។

៨. ក្រសួងសាធារណការ និងដឹកជញ្ជូន

បានរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ សេចក្តីណែនាំ ផែនការប្រតិបត្តិការងារប្រយុទ្ធនឹងជំងឺអេដស៍។

ចូលរួមអប់រំ ផ្សព្វផ្សាយ គោលនយោបាយ សេចក្តីណែនាំស្តីពីការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្លើយតបតាមរយៈសកម្មភាពវិស័យសាធារណការ និងដឹកជញ្ជូន។

កសាងផែនការសកម្មភាព ក្នុងការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍របស់លេខាធិការដ្ឋានអេដស៍ក្រសួង ។

បន្តពង្រឹងសកម្មភាពកសាងធនធានមនុស្ស ចលនាប្រកពធនធានកិច្ចសហការជាមួយដៃគូនិងម្ចាស់គម្រោង។

បានចូលរួមយ៉ាងសកម្មភាពក្នុងការអប់រំ ផ្សព្វផ្សាយ ការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដល់កម្មករសំណង់ សាធារណការដឹកជញ្ជូន ប្រជាជនចល័ត និង ក្រុមគ្រួសារ ។

៩. ក្រសួងផែនការ

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងផែនការ បានរៀបចំសំណើគម្រោងថវិកាកម្មវិធី សម្រាប់សកម្មភាពក្នុងឆ្នាំ២០១៩ ដើម្បីរួមចំណែកទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

បានបញ្ចប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចំនួន ៧៧៩,៦២២គ្រួសារ ក្នុងខេត្ត៨ (ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ កំពត កែប ព្រះសីហនុ កោះកុង និងមណ្ឌលគីរី) ដោយបានផ្តល់ប័ណ្ណក្រីក្រដល់គ្រួសារដែលមានផ្ទុកមេរោគអេដស៍ចំនួន ៣៨៤គ្រួសារ (ក្រ១៖ ១៨៨ គ្រួសារ ក្រ២៖ ១៩៦ គ្រួសារ)។

១០. ក្រសួងកិច្ចការនារី

វគ្គបណ្តុះបណ្តាលស្តីពីទំនាក់ទំនងមាតានិងយុវតីយេនឌ័រ សុខភាពបន្តពូជ សុខភាពផ្លូវភេទ ជំងឺកាមរោគ និងជំងឺអេដស៍ ដល់មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក និងអ្នកទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់ចំនួន ២ លើក នៅខេត្តសៀមរាប និងខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុប ៨០ នាក់ (ស្ត្រី ៧៥ នាក់) ដោយប្រើប្រាស់ថវិកាជាតិ។

បានរៀបចំបញ្ចូលការបង្ការការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងគម្រោងផែនការសកម្មភាព និងថវិកាជាតិ ឆ្នាំ២០១៩ ដោយមានជាវគ្គបណ្តុះបណ្តាលចំនួន ៣ លើក និងវេទិកាអប់រំចំនួន ៥ ដង ទៅដល់មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក អ្នកទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់ និងប្រជាជនទូទៅ។

១១. ក្រសួងទេសចរណ៍

- **ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "ប្រតិបត្តិករទេសចរណ៍"**

បានរៀបចំផែនការថវិកាសម្រាប់ចំណាយលើ សកម្មភាពការងារទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៨។

១២. ក្រសួងធំនាក់ធំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

បានផ្សព្វផ្សាយច្បាប់អេដស៍ចំនួន ២លើក គឺនៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន ៧២០ នាក់ (ស្រី ១២៨នាក់)។

បានបញ្ជ្រាបនូវការយល់ដឹងពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពិសេសគោលការណ៍ ៣ សូន្យ នៅគ្រប់វេទិកាផ្សព្វផ្សាយច្បាប់នានារបស់ក្រសួងបានចំនួន ១១ ក្រុង ស្រុក ក្នុងខេត្ត៥គឺខេត្តឧត្តរមានជ័យ កំពង់ស្ពឺ ព្រៃវែង បន្ទាយមានជ័យ និងខេត្តបាត់ដំបង ដោយមានអ្នកចូលរួមសរុបចំនួន ៤៦០៨នាក់ ក្នុងនោះស្រីចំនួន ១៤៤០ នាក់។

បានចែកអាវយឺតដែលមានសារអប់រំពីជំងឺអេដស៍ចំនួន ៣៥០អាវ និងស្រោមអនាម័យ ២៥៩២ស្រោម ជូនដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់របស់ក្រសួង ។

១៣. ក្រសួងពាណិជ្ជកម្ម

បានរៀបចំផែនការថវិកា សម្រាប់ចំណាយលើសកម្មភាពការងារទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៨។

បានបញ្ចូលសារអប់រំមេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីក្រសួងពាណិជ្ជកម្ម ចំនួន ៨០ នាក់ ២លើក ។

បានរៀបចំផែនការថវិកាសម្រាប់ចំណាយលើសកម្មភាពការងារ ទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២១។

១៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា

បានរៀបចំទិវាគ្រួសារ ដែលមានគ្រួសារគំរូចំនួន ៤៥០គ្រួសារ ក្នុងនោះមានគ្រួសារដែលមានផ្ទុកមេរោគអេដស៍ ៥០គ្រួសារ ។

បានចុះចែកអំណោយដល់ប្រជាជនរងគ្រោះដោយជំងឺអេដស៍ និងមេរោគអេដស៍ នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ចំនួន២៦៩នាក់ (ក្នុងមួយនាក់ទទួលបានអង្ករ៣០គីឡូ មុង១ កន្ទេល១ ភួយ១ តង់១ និងថវិកា ២០០០៛) ។

១៥. ក្រសួងបរិស្ថាន

បានរៀបចំពិធីអបអរសាទរក្រសួងបរិស្ថានចូលរួមប្តេជ្ញាបញ្ចប់អេដស៍ត្រឹមឆ្នាំ២០២៥ ក្រោមអធិបតីភាព **ឯកឧត្តមរដ្ឋមន្ត្រី សាយ សំអាល់** និងមានការចូលរួមពី អ.ជ.ប.ជ.អ ឯ.ឧ លោកជំទាវ និងមន្ត្រីក្រសួងចំនួន ២៥៦នាក់។

បានបញ្ជ្រាបការងារអេដស៍ យេនឌ័រ ទៅក្នុងសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រក្នុងវិស័យបរិស្ថាន ឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០។

បានប្រជុំពិនិត្យឡើងវិញសមាសភាពក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង។

១៦. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ស្ថានតំណាងបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ប្រចាំទីក្រុងញ៉ូវយ៉ក បានប្រគល់ពានរង្វាន់ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍ ក្នុងការបង្ការ និងថែទាំមេរោគអេដស៍ និងជំងឺអេដស៍ដែលកំពុងរក្សាទុកនៅស្ថានបេសកកម្មជូន **ឯកឧត្តម ទា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីយកមករក្សាទុកនៅកម្ពុជាវិញ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ។

១៧. ក្រសួងរ៉ែ និងថាមពល

បានរៀបចំគម្រោងថវិកាសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១។

ធ្វើសិក្ខាសាលាផ្សព្វផ្សាយពីការប្រយុទ្ធទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីក្រោមឱវាទក្រសួង។

បានចូលរួមប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាទៀងទាត់។

១៨. សកម្មភាពអនុវត្តដោយអង្គការ HACC

ការពិនិត្យ និងចងក្រងវេទិកាសម្រាប់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់៖ HACC បាននិងកំពុងបន្តតួនាទីជាលេខាធិការដ្ឋាន និងតំណាងវេទិកាហ្វុនប៉ាមបានពិនិត្យ និងជ្រើសរើសឡើងវិញនូវសមាជិកដែលជាតំណាងវេទិកាឌីហ្វុនប៉ាមសកម្មៗ មកនៅត្រឹម៥នាក់នៅតាមការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗ មកត្រឹម ៥ ក្រុមគឺ៖ EW , PWID/PWUD, MSM, TG, PLHIV។

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពវេទិកាឌីហ្វុនប៉ាម៖ ពង្រឹងសមត្ថភាពវេទិកាឌីហ្វុនប៉ាមស្តីពីការស្វែងរកការគាំទ្រ និងការអនុវត្តសកម្មភាពរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ មានអ្នកចូលរួមចំនួន ៣៤ នាក់។

កិច្ចប្រជុំប្រចាំត្រីមាសក្រុមប្រឹក្សាវេទិកាហ្វុនប៉ាម៖ បានរៀបចំឡើងដោយលេខាធិការដ្ឋាន HACC ដែលមានសមាជិកតំណាងហ្វុនប៉ាមចំនួន១៥នាក់ រួមជាមួយតំណាងមកពីស្ថាប័នពាក់ព័ន្ធ (AUA, BC, CNPUD, CPN+, KORSANG, NEWN, SMART GIRL, WNU, UNAIDS និងHACC)។

ការចុះពង្រឹងដំណើរការរបស់វេទិកាឌីហ្វុនប៉ាម៖ HACC បានចុះពង្រឹងដំណើរការរបស់វេទិកាឌីហ្វុនប៉ាមនៅតាមការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ៤ដង រួមមានខេត្ត កំពង់ស្ពឺ កោះកុង បាត់ដំបង ឧត្តរមានជ័យ តាកែវ កំពត កំពង់ឆ្នាំង កណ្តាល និងក្រចេះ ។

កិច្ចប្រជុំប្រចាំត្រីមាសរវាងអង្គការ និងសហគមន៍៖ មានអ្នកចូលរួមចំនួន៥០នាក់ រួមមានតំណាង PLHIV និង KAPs និងស្ថាប័នពាក់ព័ន្ធ។

កិច្ចប្រជុំប្រចាំឆមាសរវាងវេទិកាហ្វុនប៉ាម និងឌីហ្វុនប៉ាមជាមួយស្ថាប័នពាក់ព័ន្ធ៖ មានអ្នកចូលរួមចំនួន៥០នាក់រួមមានតំណាង PLHIV KAPs និងស្ថាប័នពាក់ព័ន្ធ។

៤.៤ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី២: បង្កើន និងរក្សាគុណភាព ការគ្របដណ្តប់ និងការរក្សាទុកគ្រប់ជំហានទាំងអស់នៅក្នុងការថែទាំ ព្យាបាលបន្តដោយយកឥស្សរជន និងការណែនាំជាមូលដ្ឋាន

៤.៤.១ អតិថិជនមកទទួលសេវាផ្តល់ការប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយ ស្ម័គ្រចិត្ត និងរក្សាការសម្ងាត់

យោងទៅតាមទិន្នន័យដែលអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបានពីរាជធានី ខេត្ត ចំនួន២២ ក្នុងត្រីមាសទី១ ឆ្នាំ២០១៨ នេះ មានអតិថិជនមកទទួលសេវាផ្តល់ការប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សរុបចំនួន២៦៨៤២ នាក់ ក្នុងនោះលទ្ធផលតេស្តវិជ្ជមានមានចំនួន៥៦៧នាក់។ អាស្រ័យហេតុនេះអត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមអតិថិជនដែលបានមកទទួលការប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍គឺមានចំនួន ២.០៧%។ (តារាងទី១៣) (ឧបសម្ព័ន្ធ១០)។

តារាងទី១៣: ចំនួនប្រជាជនដែលបានទទួលសេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ក្នុងខេត្តចំនួន២២

សូចនាករ	លទ្ធផលតេស្តថ្មីមាន	លទ្ធផលតេស្តអវិជ្ជមាន	អត្រាផ្ទុកមេរោគអេដស៍ (%)
ចំនួន (#)ប្រជាជនទទួលសេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍។	៥៦៧	២៦៨៤២	២.០៧

៤.៤.២ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

ក្នុងចំណោមទិន្នន័យដែលអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានទទួលពីសេវាថែទាំសុខភាពសាធារណៈទាំង២២ រាជធានី ខេត្ត ក្នុងត្រីមាសទី១ឆ្នាំ២០១៨ នេះ មានតែ១៨ រាជធានី ខេត្ត ដែលមានទិន្នន័យ ស្តីពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅក្នុងនោះមានស្ត្រីមានផ្ទៃពោះចំនួន ៧១៤០៩នាក់ បានមកពិនិត្យផ្ទៃពោះលើកដំបូង (តារាងទី១៤)។

តារាងទី១៤: ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យថែទាំផ្ទៃពោះលើកដំបូងដោយបែងចែកទៅតាមការប្រើប្រាស់សេវា

សូចនាករ	ចំនួន		សរុប
	សេវាសាធារណៈ	ចុះពិនិត្យផ្ទាល់	
ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យថែទាំ ផ្ទៃពោះលើកដំបូង	៧១៤០៩នាក់	០	៧១៤០៩នាក់

ក្នុងចំណោមស្ត្រីមានផ្ទៃពោះចំនួន៧១៤០៩នាក់ ដែលបានមកទទួលសេវាពិនិត្យ និងថែទាំផ្ទៃពោះដំបូង មានស្ត្រីមានផ្ទៃពោះចំនួន ៦៤៦៥២នាក់ បានទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ក្នុងនោះមានស្ត្រីមានផ្ទៃពោះចំនួន៥៥៦១៥នាក់ មិនធ្លាប់បានទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ និងមានស្ត្រីចំនួន ៩០៣៧នាក់ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពីមុនរួចមកហើយ (តារាងទី១៥)។

តារាងទី១៥ : ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យផ្ទៃពោះលើកដំបូងដោយបែងចែកទៅតាមប្រភេទក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍

សូចនាករ	ចំនួន		សរុប
	មិនធ្លាប់ធ្វើតេស្ត	ធ្លាប់ធ្វើតេស្ត	
ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យថែទាំផ្ទៃពោះលើកដំបូងដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍	៥៥៦១៥នាក់	៩០៣៧នាក់	៦៤៦៥២នាក់

បើនិយាយពីលទ្ធភាពក្នុងការទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យ និងថែទាំផ្ទៃពោះលើកដំបូងគឺមាន

ចំនួន៧១៤០៩នាក់ ក្នុងនោះមានស្ត្រីចំនួន៦៤៦៥២នាក់ ដែលទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្ត ឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ដែលស្មើនឹង៩០,៥៤% (តារាងទី១៦)។

តារាងទី១៦: អត្រាស្ត្រីមានផ្ទៃពោះ បានទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់

សូចនាករ	ចំនួនស្ត្រីដែលបានពិនិត្យផ្ទៃពោះដំបូង	ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះដំបូងដែលបានធ្វើតេស្ត	ភាគរយ
អត្រាស្ត្រីមានផ្ទៃពោះដែលទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់	៧១៤០៩នាក់	៦៤៦៥២នាក់	៩០,៥៤%

ក្នុងចំណោមស្ត្រីមានផ្ទៃពោះចំនួន ៦៤៦៥២នាក់ ដែលបានទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តគឺមានស្ត្រីមានផ្ទៃពោះចំនួន ១២៦៦៤នាក់ បានដឹងពីលទ្ធផលតេស្តគឺស្មើនឹង ១៩,៥៩ ភាគរយ (តារាងទី១៧)។

តារាងទី១៧: អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលលទ្ធផលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់

សូចនាករ	ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះដំបូងដែលបានធ្វើតេស្ត	ចំនួនស្ត្រីមានផ្ទៃពោះដែលដឹងលទ្ធផលតេស្ត	ភាគរយ
អត្រាស្ត្រីមានផ្ទៃពោះដែលបានទទួលលទ្ធផលតេស្តឈាមរកមេរោគអេដស៍	៦៤៦៥២នាក់	១២៦៦៤នាក់	១៩,៥៩

ក្នុងចំណោមស្ត្រីមានផ្ទៃពោះចំនួន ១២៦៦៤នាក់ ដែលបានទទួលលទ្ធផលពីការធ្វើតេស្តឈាមរកមេរោគអេដស៍ មានស្ត្រីមានផ្ទៃពោះដែលមានលទ្ធផលវិជ្ជមានចំនួន៤៣នាក់ គឺស្មើនឹង ០.៣៥%។ (តារាងទី១៨)។

តារាងទី១៨: អត្រាឆ្លុកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលបាន ធ្វើតេស្តរកមេរោគអេដស៍

សូចនាករ	ចំនួនស្ត្រីមានផ្ទៃពោះដែលបានទទួលលទ្ធផលធ្វើតេស្ត	ចំនួនស្ត្រីមានផ្ទៃពោះដែលមានលទ្ធផលតេស្តវិជ្ជមាន	ភាគរយ
អត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍	១២៦៦៤នាក់	៤៣នាក់	០.៣៥

នៅក្នុងរយៈពេលដូចគ្នានេះដែរ មានស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលការព្យាបាល បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន៤០នាក់ ហើយស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មានចំនួន ៧៤នាក់ និងស្ត្រីដែលមានផ្ទៃពោះផ្ទុកមេរោគអេដស៍បានទទួលការបង្ការការចម្លងមេរោគអេដស៍ ពីម្តាយទៅកូនក្នុងពេលសំរាលចំនួន២៧នាក់ (តារាងទី១៩)។

តារាងទី១៩: លទ្ធផលនៃស្ត្រីមានផ្ទៃពោះដែលទទួលសេវាបង្ការការចម្លងមេរោគ អេដស៍ពីម្តាយទៅកូន

សូចនាករ		**ចំនួន**
១	ចំនួនស្ត្រីមានផ្ទៃពោះទទួលការព្យាបាលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន	៤០
២	ចំនួនស្ត្រីមានផ្ទៃពោះទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍	៧៤
៣	ចំនួនស្ត្រីមានផ្ទៃពោះទទួលការព្យាបាលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្នុងពេលសំរាល	២៧

៤.៤.៣ សមិទ្ធផលនៃការផ្តល់សេវា

យោងទៅតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ គិតត្រឹមត្រីមាសទី៤ឆ្នាំ២០១៧ នេះ មាន៦៩កន្លែងដែលបានផ្តល់សេវាថែទាំ និងព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដែលស្ថិតនៅក្នុងស្រុកប្រតិបត្តិចំនួន ៥៦កន្លែង នៅក្នុង ២៥ រាជធានី ខេត្ត ដូនដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលក្នុងនោះ មាន៤១កន្លែងដែលមានផ្តល់សេវាថែទាំ និងព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ដល់កុមារ។

៤.៤.៣.១ សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

ក. សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ (VCCT)

ចំនួនមណ្ឌលផ្តល់សេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧ នេះមាន ៧០កន្លែង។ ក្នុងចំណោមមណ្ឌលផ្តល់សេវាប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់ទាំង៧០កន្លែង មាន៦៥កន្លែងដែលគ្រប់គ្រងដោយសេវាសុខភាពសាធារណៈ និង៥កន្លែងដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល (អង្គការ MEC ចំនួន១ អង្គការ Center of Hope ចំនួន១ វិទ្យាស្ថាន Pasteur ចំនួន១ និងគ្លីនិកឈូកសចំនួន២កន្លែង)។ ទន្ទឹមនឹងនេះ សេវាធ្វើតេស្តឈាមរកមេរោគអេដស៍រហ័សដោយជោះឈាមនៅចុងម្រាមដៃ បានពង្រីកដល់មណ្ឌលសុខភាពដែលមានចំនួនជាង ១០៤៩ កន្លែង ។

ខ. ការផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍

គិតរហូតដល់ត្រីមាសទី៤ ឆ្នាំ២០១៧ អតិថិជនដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់មានចំនួន

៧០.៦៦៥នាក់ (ប្រហែល ៩៨,៣១% នៃចំនួនអតិថិជនចំនួន ៧១.៨៨១នាក់ ដែលមកពីសេវានានា) ដែលក្នុងនោះមាន៖

- កុមារអាយុស្មើឬតិចជាង ១៤ឆ្នាំ ចំនួន២.៦៧៧ នាក់ (៣.៧៨%)
- អតិថិជនមានអាយុចាប់ពី ១៥ ដល់ ៤៩ឆ្នាំ ចំនួន៥៩.៤៦៤នាក់ (៨៤.១៤%)
- អតិថិជនមានអាយុលើសពី ៤៩ឆ្នាំ មានចំនួន ៨.៥២៤នាក់ (១២.០៦%)
- អតិថិជនជាស្ត្រីចំនួន ៣៧.៨៧៧នាក់ (៥២.៨៩%)
- អ្នកជំងឺរបេងធ្វើតេស្តឈាមរកមេរោគអេដស៍ចំនួន ៤.០៤២នាក់ ដែលមានតេស្តវិជ្ជមានមេរោគអេដស៍ មានចំនួន៧៩នាក់។
- អតិថិជនសរុបចំនួន៣.៧០៩នាក់ (៥.២៤%) (រួមទាំងអ្នកជំងឺរបេង) ដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍មានលទ្ធផលវិជ្ជមាននៃការឆ្លងមេរោគអេដស៍ នៅតាមមណ្ឌលផ្តល់សេវាប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្មគ្រ័ចិត្ត និងក្សាការសម្ងាត់ទូទាំងប្រទេស។

គ. ការផ្តល់សេវាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍

គិតរហូតដល់ចុងត្រីមាសទី៤ ឆ្នាំ២០១៧ មានអតិថិជនចំនួន ៧០.០៩៣នាក់ (៩៩.១៩%) នៃអតិថិជនសរុប (៧០.៦៦៥នាក់) ដែលធ្វើតេស្តឈាមមេរោគអេដស៍បានទទួលលទ្ធផល និងការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមរកមេរោគអេដស៍នៅមណ្ឌល VCCT ទូទាំងប្រទេស។

ឃ. សេវាថែទាំ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

គិតមកត្រឹមចុងត្រីមាសទី៤ ឆ្នាំ២០១៧ មានសេវាថែទាំ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន៦៩កន្លែង ដែលស្ថិតនៅក្នុងស្រុកប្រតិបត្តិចំនួន៥៦ នៅក្នុងរាជធានី ខេត្ត ចំនួន២៥។ ក្នុងចំណោមសេវាទាំង៦៩កន្លែង គឺសេវាចំនួន ៦៥ កន្លែងស្ថិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាល និងសេវាចំនួន៤កន្លែងទៀតដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល និងមាន សេវាទទួលការពិនិត្យ និងព្យាបាលជំងឺកុមារផ្ទុកមេរោគអេដស៍ចំនួន ៤១កន្លែង នៅក្នុងស្រុកប្រតិបត្តិចំនួន ៣៥។

គិតត្រឹមចុងត្រីមាសទី៤ ឆ្នាំ២០១៧ មានអ្នកជំងឺសកម្មសរុបចំនួន ៥៨.៥១៦ នាក់ដែលក្នុងនោះមាន ៥៥.១០៨នាក់ ជាមនុស្សពេញវ័យ និង ៣,៤០៨ នាក់ ជាកុមារកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ (រូបភាពទី១)។

រូបភាពទី១: និន្នាការចំនួនទីកន្លែង និងអ្នកផ្តុំកមេរោគអេដស៍ដែលផ្តល់ និងទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ ២០០១ ដល់ត្រីមាសទី៤ ឆ្នាំ ២០១៧



គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០១៧ មានអ្នកផ្តុំកមេរោគអេដស៍ និងជំងឺអេដស៍ពេញវ័យចំនួន ៥៥,១០៨នាក់ និងកុមារចំនួន ៣,៤០៨នាក់ កំពុងទទួលសេវាផ្តល់ឱសថប្រឆាំងមេរោគអេដស៍។ (រូបភាពទី២)។

រូបភាពទី២: និន្នាការអ្នកផ្តុំកមេរោគអេដស៍កុមារ និងមនុស្សពេញវ័យដែលបានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ ២០១៣ ដល់ត្រីមាសទី៤ ឆ្នាំ ២០១៧។



ឧ. ការបញ្ជូនអ្នកជំងឺទៅទទួលសេវាកន្លែងផ្សេងការបោះបង់ការព្យាបាល និងការស្លាប់

គិតរហូតដល់ចុងត្រីមាសទី៤ ឆ្នាំ២០១៧ មានចំនួនអ្នកជំងឺដូចខាងក្រោម៖

- មានអ្នកជំងឺចំនួន៣.៨៩៦នាក់ (ដែលមានអ្នកជំងឺពេញវ័យចំនួន ៣.៥៨២នាក់ និងកុមារចំនួន ៣១៤នាក់) កំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបានបញ្ជូនទៅទទួលសេវាART ថ្មីដែលស្ថិតនៅជិតពួកគេ។
- មានអ្នកជំងឺដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន ១.៩៦៦នាក់ បានបោះបង់ការព្យាបាល (ដែលមានអ្នកជំងឺពេញវ័យចំនួន ១.៨៤៦នាក់ និងកុមារចំនួន ១២០នាក់)។
- មានអ្នកជំងឺចំនួន៦៩៥នាក់ ផ្សេងទៀតបានស្លាប់ (អ្នកជំងឺពេញវ័យចំនួន៦៧០នាក់ និងកុមារចំនួន២៥នាក់)។

៤.៥ ទស្សនាភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៣: កាត់បន្ថយផលប៉ះពាល់ នៃមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការបង្កើនការគ្របដណ្តប់ អន្តរាគមន៍ដែលមានគុណភាព និងប្រសិទ្ធភាព

ការបញ្ចូលគ្រួសាររងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជនងាយរងគ្រោះក្នុងដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ៖

- សម្របសម្រួលរៀបចំកិច្ចប្រជុំក្រុមការងារបង្កើតបរិយាកាសគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នៅខេត្តបន្ទាយមានជ័យ។
- បានរៀបចំបញ្ជីឈ្មោះអ្នកផ្តុំកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដើម្បីចងក្រងបញ្ជីគ្រួសារក្រីក្រសម្រាប់សម្ភាស និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកជំងឺអេដស៍ ដើម្បីផ្ញើទៅក្រសួងផែនការរួមមានខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ និងរាជធានីភ្នំពេញ ឆ្នាំ២០១៨។ (តារាងទី២០)(ឧបសម្ព័ន១១)។

តារាងទី២0: សមិទ្ធផលនៃកុមារជាប់រងគ្រោះដោយសារជំងឺអេដស៍បានទទួលការគាំទ្រសង្គមក្នុងខេត្តចំនួន៣

សូចនាករ	ចំនួនកុមារជាប់រងគ្រោះបានទទួលការគាំទ្រសង្គម	ចំនួនកុមារជាប់រងគ្រោះគោលដៅ	សមិទ្ធផល (%)
ចំនួន (#) កុមារងាយរងគ្រោះរាជធានី ខេត្តដែលបានទទួលការគាំទ្រសង្គម។	១៦៥	៣៨០១	៤.៤៣

៤.៦ ឫទ្ធានភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៤: ការដឹកនាំ សម្របសម្រួលភាគីពាក់ព័ន្ធ ការកៀរគរ និងបែងចែកធនធាន (ជាយុទ្ធ សាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទាំង៥ទៀត)

ក្នុងការពង្រឹងការដឹកនាំការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគ អេដស៍ និងជំងឺអេដស៍ នៅទូទាំងប្រទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រើប្រាស់នូវវេទិកា ចំបងដូចជាកិច្ចប្រជុំ ការបណ្តុះបណ្តាល និងការចុះប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងគណៈកម្មាធិការ ប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងរដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត ខណ្ឌ ស្រុក ក្រុង និងសង្កាត់ ឃុំ ដើម្បី ត្រួតពិនិត្យនូវវឌ្ឍនភាព បញ្ហាការលំបាក និងផ្តល់ការគាំទ្រជាដំណោះស្រាយ ឬជាអនុសាសន៍។ល។

៤.៦.១ ការងារដឹកនាំ គ្រប់គ្រង សម្របសម្រួលការឆ្លើយតបទូលំទូលាយ និងពហុ វិស័យទៅនឹងមេរោគអេដស៍ ជំងឺអេដស៍

- កិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអនុម័តជាគោលការណ៍នូវការ រៀបចំផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣ ។

- កិច្ចប្រជុំក្រុមការងាររួមគ្នារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍលើការងារប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៨ ដោយសំរេចបាននូវ:

  - ការធ្វើបច្ចុប្បន្នភាពស្តីពីការអនុវត្តគម្រោងមូលនិធិសកលឆ្នាំ២០១៨ ដល់២០២០។
  - ឯកភាពលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការឆ្លើយតបមេរោគអេដស៍ និង ជំងឺអេដស៍ជាពហុវិស័យលើកទី៥។
  - ឯកភាពលើរបាយការណ៍វាយតម្លៃ លើការត្រៀមឆ្លើយតបការងារចំពោះមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលអន្តរកាល។

- ឯកឧត្តមប្រធាន អ.ជ.ប.ជ.អ បានដឹកនាំកិច្ចប្រជុំលើកទី២ នៃយន្តការសម្របសម្រួល មូលនិធិសកលសម្រាប់មណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិច នៃក្រុមប្រឹក្សាភិបាលមូលនិធិសកល នាថ្ងៃ ទី២៥ ខែ មេសា ឆ្នាំ២០១៨ នៅសណ្ឋាគារអង្គរសិនជូរី ខេត្តសៀមរាប។ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសកលសម្រាប់មណ្ឌលតំបន់អាស៊ីប៉ាស៊ីភិច។

- ថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ បានដឹកនាំសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល មូលនិធិសកលកម្ពុជា (CCC) ដើម្បីពិភាក្សា និងពិនិត្យទៅលើវឌ្ឍនភាព និងលក្ខខណ្ឌសម្រាប់ការ ចាប់ផ្តើមនៃការអនុវត្តគម្រោងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់សម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។

- ពិធីផ្ទេរតំណែងប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងប្រធានគណៈកម្មាធិការសម្របសម្រួលមូល និធិសកល (CCC) ជូនដល់**ឯកឧត្តម ហែម វណ្ណឌី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានអាណត្តិថ្មីរបស់ CCC នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ បានសម្របសម្រួលកិច្ចប្រជុំក្រុមការងារជាន់និរន្តរភាពនៃការ ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ២លើក ដោយសម្រេចបានឯកសារស្តីពីការវាយតម្លៃលើការ ត្រៀមឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានផែនទីចង្អុលផ្លូវ (Roadmap) បង្ហាញពី ការប្រឈម (Identify Risk)ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ដំណាក់កាលអន្តរកាល។

- អគ្គលេខាធិការដ្ឋានបានសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ ចំនួន៤លើក

- ធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី២ ឆ្នាំ ២០១៧។
- រៀបចំរបាយការណ៍វឌ្ឍនភាពជាទៀងទាត់ស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- ចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ ស្តីពីការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ពីក្រសួង ស្ថាប័ន និងអង្គការជាដៃគូ។
- ពិភាក្សាស្វែងរកដំណោះស្រាយការងារបច្ចេកទេស ជូនសមាជិកអ.ជ.ប.ជ.អ ។

- ថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ បានអញ្ជើញជាអធិបតីទទួលអំណោយអាហារបំប៉ន់សុខភាព ខេមប្រូ ប៊ីយូទិក (KEM Probiotic) ពីមូលនិធិគីណាល់ តំណាងដោយលោកឱសថបណ្ឌិត **ហៃ លីអ៊ាង** ប្រធានមូលនិធិ និងជាប្រធានសហគ្រាសផលិតឱសថប៉េប៉េអឹម និងក្រុមហ៊ុនខនហ្វីរេល។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារ បច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមបុរសស្រលាញ់បុរស និងស្ត្រីស្រស់ដើម្បី តាមដានវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនការ។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ដឹកនាំកិច្ចពិភាក្សាលើសំណើសុំកិច្ចសហការជាមួយ ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងការអនុវត្តកម្មវិធីយុទ្ធនាការផ្សព្វផ្សាយអប់រំអំពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងសហគមន៍តាមបណ្តាយផ្លូវជាតិលេខ៣ (កំពត-វាលរេញ) និងផ្លូវជាតិលេខ ៧ (ត្បូងឃ្មុំ-ក្រចេះ) ក្រោមគម្រោងគ្រប់គ្រងផ្លូវថ្នល់ទី២ (Road Asset Management Project-II: RAMP-II) ។

៤.៧ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៥: បង្កនិងបង្កើតបរិស្ថានការគាំទ្រតាមរយៈការយល់ដឹងនិងការអនុវត្តច្បាប់ និងគោលនយោបាយឱ្យកាន់តែប្រសើរឡើង

អ.ជ.ប.ជ.អ បន្តសហការជាមួយគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលក្នុងការ បន្តស្វែងរកការគាំទ្រថវិកាជាបន្តទៀតក្រោយឆ្នាំ២០១៩។

អ.ជ.ប.ជ.អ បន្តសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបង្កើនថវិកាជាតិ ដើម្បីបំពេញនូវការធ្លាក់ចុះនូវការគាំទ្រថវិកាអន្តរជាតិជាបន្តបន្ទាប់។

អ.ជ.ប.ជ.អ បានបញ្ចប់នូវការកសាងគំរោងផែនការថវិកាជាតិឆ្នាំ២០១៩ ដើម្បីស្នើសុំការ អនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អ.ជ.ប.ជ.អ បានសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការបញ្ជ្រាបថវិកាប្រយុទ្ធនឹងជំងឺ អេដស៍ ទៅក្នុងផែនការវិនិយោគឃុំ សង្កាត់ ។

៤.៨ វឌ្ឍនភាព និងសមិទ្ធផលក្នុងការអនុវត្តយុទ្ធសាស្ត្រទី៦: បង្កើនប្រព័ន្ធតាមដាន និងវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងដំណឹអេដស៍តែមួយ(រាំងក្នុងវិស័យសុខាភិបាលនិងវិស័យដទៃទៀត)(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រចាំង ៥ ទៀត)

៤.៨.១ គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ

គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៨ និងបានធ្វើការពិនិត្យឡើងវិញឱ្យបានសមស្របទៅនឹងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងដំងឺអេដស៍លើកទី៤ (ឆ្នាំ២០១៥-ឆ្នាំ២០២០) ដែលក្នុងនោះមានការកែសម្រួលមួយចំនួនទៅលើប្រព័ន្ធលំហូរទិន្នន័យ និងមានការកែសម្រួលលើការកំណត់នូវសូចនាករមួយចំនួន និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យផងដែរ។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាតិនេះគឺអាចធានាបាននូវការចាប់យកទិន្នន័យនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងដំងឺអេដស៍នៅទូទាំងប្រទេសដោយមានការលំហូរពីថ្នាក់មូលដ្ឋានដូចជាមកពីគណៈកម្មាធិការប្រយុទ្ធនឹងដំងឺអេដស៍ ក្រុង ស្រុក ខណ្ឌ លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធនឹងដំងឺអេដស៍រាជធានីខេត្តមកលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធនឹងដំងឺអេដស៍ ក្រសួងរដ្ឋលេខាធិការដ្ឋាន និងចុងក្រោយបំផុតគឺមកនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ដែលជាអ្នកគ្រប់គ្រង និងវិភាគទិន្នន័យទាំងអស់នោះឱ្យក្លាយជាព័ត៌មាននៃការឆ្លើយតបជាតិទៅនឹងការរាលដាលមេរោគអេដស៍ ហើយធ្វើការចងក្រងឱ្យទៅជារបាយការណ៍ជាតិ។

គោលការណ៍ណែនាំជាតិបានកំណត់ច្បាស់នូវការវាស់វែងពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលពីការអនុវត្ត " ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងដំងឺអេដស៍លើកទី៤ " ។

៤.៨.២ ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព

- នៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងដំងឺអេដស៍។ រៀបចំ និងសម្របសម្រួលក្នុងសិក្ខាសាលាវិបស្សនា ស្តីពីការពិគ្រោះយោបល់លើការងារដែលបានអនុវត្តនៅក្នុងឆ្នាំ២០១៨ និងពិនិត្យពិភាក្សាផែនការសម្រាប់ ឆ្នាំ២០១៨ នៅខេត្តកោះកុង។

- បានដឹកនាំ និងសម្របសម្រួលក្រុមការងារជាតិក្នុងការពិភាក្សា ស្តីពីការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងដំងឺអេដស៍លើកទី៥ ដោយបានបង្កើតក្រុមការងារយុទ្ធសាស្ត្ររៀបចំគម្រោងផែនការសកម្មភាព និងតម្រូវការថវិកា ។

- បាននិងកំពុងចូលរួមផ្តល់ធាតុចូលសម្រាប់ធ្វើផែនការយុទ្ធសាស្ត្រ(SNDP)អភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដែលសម្របសម្រួលដោយក្រសួងផែនការ។

- បានបញ្ចប់ផែនការសកម្មភាពនាយកដ្ឋាន និងផែនការសកម្មភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៨ និងឆ្នាំ២០១៩។

៤.៨.៣ ការគ្រប់គ្រងទិន្នន័យ

- នៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ ទាក់ទងនឹងក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យជាតិ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបន្តការប្រើប្រាស់កម្មវិធីរបស់ជាតិដ៏មានសក្តានុពលក្នុងការរក្សាទុកទិន្នន័យ និងការប្រើប្រាស់បានទូលំទូលាយ។ ម្យ៉ាងទៀតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបញ្ជូនមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យទៅអភិបាលនៅថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលដល់ការងារគ្រប់គ្រងទិន្នន័យឱ្យបានកាន់តែប្រសើរ។

- បានរៀបចំរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទូលំទូលាយ និង ពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍២០១៧ (GARPR 2017) ផ្ញើជូនទៅអង្គការសហប្រជាជាតិ។

- អ.ជ.ប.ជ.អ បានសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងការធ្វើបច្ចុប្បន្នភាព Spectrum File ដើម្បីប៉ាន់ស្មាន និងទស្សន៍ទាយពីចំនួន និងអត្រាផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ (HIV estimates and projections) ។

៤.៨.៤ ការផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មាន

ក. ការរៀបចំ និងផ្សព្វផ្សាយរបាយការណ៍

ជាលទ្ធផលសំរាប់ឆ្នាំ២០១៨នេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំជាបន្តបន្ទាប់នូវរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលក្នុងទម្រង់ជារបាយការណ៍ប្រចាំខែ ប្រចាំឆមាស បានជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដើម្បីផ្ញើជូនទៅរាជរដ្ឋាភិបាល រដ្ឋសភាជាតិ ដៃគូអភិវឌ្ឍ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

ខ. ការរៀបចំ និងផ្សព្វផ្សាយតាមគេហទំព័រ

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបន្តគ្រប់គ្រង និងដាក់បញ្ចូលជាបន្តបន្ទាប់នូវឯកសារថ្មីៗទាំងអស់ដែលបានផលិតចេញដោយសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ទៅក្នុងគេហទំព័ររបស់ អ.ជ.ប.ជ.អ ។ នៅក្នុងឆមាសទី១នេះដែរ មានឯកសារ និងព័ត៌មានថ្មីៗជាច្រើនដែលបានដាក់បញ្ចូលនៅក្នុងគេហទំព័រដែលក្នុងនោះរួមមានព័ត៌មានស្តីពីកិច្ចប្រជុំថ្នាក់ដឹកនាំ ពីវគ្គបណ្តុះបណ្តាល ពីសិក្ខាសាលា ពីកិច្ចប្រជុំថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ពីព័ត៌មានវិទ្យាសាស្ត្រនានា ព្រមទាំងរបាយការណ៍ផ្សេងៗជាច្រើនទៀត ក្នុងនោះមាន អ.ជ.ប.ជ.អ បានធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ខ្លួនជាទៀងទាត់ ដោយបានដាក់បញ្ចូលឯកសារបានចំនួន៦៩ ដោយមានអ្នកចូលអានចំនួន៥៦៦១ នាក់ (ខែតុលា ឆ្នាំ២០១៧ ដល់ ខែឧសភា ឆ្នាំ២០១៨)។

៤.៨.៥ ពង្រឹងការត្រួតពិនិត្យការចំណាយថវិការទៅលើជំងឺអេដស៍

ដើម្បីតាមដានឱ្យបានជាប្រចាំនូវការចំណាយជាតិទៅលើការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសម្របសម្រួលការសិក្សាស្តីពីការអង្កេតជាតិការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០១៦ និង ឆ្នាំ២០១៧ (NASA VI 2016-2017)។

៥. ផែនកំណត់

នៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ ជាការកត់សំគាល់ឃើញថាការផ្តល់របាយការណ៍ មានលក្ខណៈល្អប្រសើរជាងឆមាសមុនៗទាំងបរិមាណ និងគុណភាព។ ក្នុងនោះចំនួនទម្រង់ប្រមូលទិន្នន័យបានកើនឡើងរហូតដល់ ១៨ ក្រសួង (ក្នុង២៦ក្រសួង ស្ថាប័ន) ២២ រាជធានី ខេត្ត (ខេត្តដែលមិនបានផ្ញើគឺ ខេត្តព្រះវិហារ ស្ទឹងត្រែង និងខេត្តព្រះសីហនុ) និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៥។

ចំពោះសមាជិក អ.ដ.ប.ដ.អ ដែលបានផ្ញើទិន្នន័យ ឬរបាយការណ៍មក អ.ដ.ប.ដ.អ គឺនៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយគឺនៅមានគម្លាត និងខ្វះសុក្រិតភាពនៃទិន្នន័យ ឬព័ត៌មានឧទាហរណ៍គម្លាតចំនួនក្រុមគោលដៅគម្លាតចំនួនសេវា ។ល។

ភាពយឺតយ៉ាវនៃការទទួលបាននូវ ថវិកាជំនួយសម្រាប់ការចំណាយនាំឱ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់ការពន្យាពេលក្នុងការអនុវត្តសកម្មភាពគន្លឹះមួយចំនួនដូចជាកិច្ចប្រជុំដឹកនាំ គ្រប់គ្រង និងសម្របសម្រួលរបស់ គណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

លើសពីនេះទៅទៀត ស្ថានភាពនៃកត្តាប្រឈមនឹងការចម្លងមេរោគអេដស៍ និងស្ថានភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ មានការប្រែប្រួលខ្លាំងណាស់ដែលអាចរារាំងផងដែរទៅដល់វឌ្ឍនភាព និងសមិទ្ធផលនៅក្នុងឆមាសទី១ ឆ្នាំ២០១៨នេះដូចជា:

- ចំនួនគ្រឹះស្ថានកម្សាន្តសប្បាយ និងចំនួនស្ត្រីបំរើសេវានៅតាមគ្រឹះស្ថានកម្សាន្តសប្បាយមានការកើនឡើង។
- ចំនួនអង្គការសង្គមស៊ីវិល និងគម្រោងផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍មួយចំនួនត្រូវបញ្ចប់ដោយសារតែគ្មានការគាំទ្រថវិកា ជាពិសេសគម្រោងដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារនៅតាមសហគមន៍ និងក្រុមគោលដៅដែលប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍។
- នៅមានឃុំ សង្កាត់ និងអន្តរមន្ទីរមួយចំនួនធំដែលមិនទាន់បានបញ្ចូល ឬបញ្ជាបការងារអេដស៍ទៅក្នុងផែនការសកម្មភាពស្នូលរបស់ខ្លួននៅឡើយ។
- នៅមានការលំបាកក្នុងការចុះអប់រំផ្សព្វផ្សាយដោយផ្ទាល់ ទៅដល់ស្ត្រីបំរើសេវាកម្សាន្តមួយចំនួនដូចជាកាស៊ីណូ និងការ៉ាអូខេ (ខេត្តព្រះសីហនុ) ដោយពិបាកសម្របសម្រួលជាមួយថៅកែជនជាតិបរទេស។ល។
- នៅមានកម្មករ កម្មការនី តាមរោងចក្រជាច្រើនដែលមិនទាន់ទទួលបានការអប់រំផ្សព្វផ្សាយស្តីពីការបង្ការការចម្លងមេរោគអេដស៍ និងជំងឺអេដស៍។
- នៅមានសេវាកម្សាន្តមួយចំនួនមិនទាន់មានការតាំងលក់ស្រោមអនាម័យនៅឡើយ។
- ការចូលរួមរបស់អាជ្ញាធរដែនដីនៅតាមថ្នាក់ក្រោមជាតិមួយចំនួននៅមានកម្រិតនៅឡើយ។

៦. សេចក្តីសន្និដ្ឋាន

កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជានៅតែទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ថាជាកម្មវិធីអាទិភាពមួយខ្ពស់ក្នុងចំណោមបណ្តាអាទិភាពដទៃទៀតនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលកម្ពុជានៅបន្តការប្តេជ្ញាចិត្តយ៉ាងមោះមុត ក្នុងការចូលរួមជាមួយសកលលោកតាមរយៈអង្គការសហប្រជាជាតិក្នុងការអនុវត្តយុទ្ធសាស្ត្របីសូន្យ (គឺគ្មានការឆ្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់ដោយជំងឺអេដស៍)។

ក្នុងចំណោមយុទ្ធសាស្ត្រទាំង៦ គឺមានការអនុវត្តបានប្រសើរទៅតាមគម្រោងផែនការសកម្មភាពដែលបានគ្រោងទុក។ ការដឹកនាំគ្រប់គ្រង និងសម្របសម្រួលតាមរយៈគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍កាន់តែមានលទ្ធភាព និងប្រសិទ្ធភាពប្រសើរឡើងតាមរយៈការរៀបចំគម្រោងផែនការ ការចុះអនុស្សារណៈ ការរៀបចំកិច្ចប្រជុំជាទៀងទាត់។ល។

ប្រសិទ្ធភាពនៃការបង្ការអាចមានចីរភាព បានរួមជាមួយនឹងការបង្កើននូវអត្រាគ្របដណ្តប់ទៅលើភូមិសាស្ត្រនិងក្រុមគោលដៅតាមរយៈកម្មវិធីឆ្លើយតបសហគមន៍។

តាមរយៈការពង្រីកនូវកម្មវិធីឆ្លើយតបរួមគ្នា ស្ត្រីមានផ្ទៃពោះកាន់តែមានលទ្ធភាពច្រើនឡើងក្នុងការទទួលបាននូវសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ប្រកបដោយក្តីសង្ឃឹមក្នុងការឈានទៅសម្រេចបាននូវគោលដៅគ្មានការចម្លងមេរោគអេដស៍ថ្មីពីមាតាទៅទារកនា ឆ្នាំ២០២០។

កម្ពុជានៅតែមានលទ្ធភាពប្រកបដោយចីរភាព ក្នុងការផ្តល់សេវាថែទាំនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានលើសពី៩០ភាគរយ (៩០- ៩០- ៩០) និងប្រកបដោយគុណភាពជីវិតតាមរយៈការពង្រីកនូវប្រព័ន្ធគាំទ្រមន្ទីរពិសោធន៍ និងប្រព័ន្ធត្រួតពិនិត្យគុណភាពសេវា និងគុណភាពនៃការគោរពតាមការព្យាបាលពីអ្នកប្រើប្រាស់សេវា។

ប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ បានបង្ហាញថាការរាលដាលមេរោគអេដស៍នៅកម្ពុជា ជាទូទៅមានការបន្តធ្លាក់ចុះជាបន្តទៀត ទោះបីនៅមានការព្រួយបារម្ភខ្លះចំពោះក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន និងក្រុមបុរសស្រឡាញ់បុរស។

ការងារដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបពហុវិស័យ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយចីរភាព។

ការងារបង្ការជាពិសេសទៅលើក្រុមគោលដៅមានសន្ទុះគួរឱ្យចាប់អារម្មណ៍ ក្នុងការឈានទៅបង្កើនអត្រាគ្រប់ដណ្តប់ឱ្យបានកាន់តែខ្ពស់ តាមរយៈកម្មវិធីបង្កើនលទ្ធភាពក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍។

ការងារថែទាំ និងព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍មាននិន្នាការកើនឡើងជាលំដាប់ប្រកបដោយក្តីសង្ឃឹមខ្ពស់រហូតសម្រេចបាននូវគោលដៅ៩០.៩០.៩០ ក្នុងចំណោមប្រទេសទាំង៧។

ពុំទាន់មានបាយការណ៍ណាមួយដែលបង្ហាញពីការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលជាក្តីសង្ឃឹមមួយទៀតក្នុងការឈានទៅលុបបំបាត់បានទាំងស្រុងនូវការរើសអើង និងមាក់ងាយទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

ទោះបីជាកម្ពុជាកំពុងតែប្រឈមនឹងបញ្ហាកាត់បន្ថយនូវថវិកាពីសហគមន៍អន្តរជាតិ ពីដៃគូអភិវឌ្ឍក៏ពិតមែន តែលទ្ធផលនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ គឺនៅតែមានចីរភាពនៅឡើយដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ខាងលើ។

ការចូលរួមនៅថ្នាក់ក្រោមជាតិឃើញថាមានសន្ទុះគួរឱ្យចាប់អារម្មណ៍ ជាពិសេសការចូលរួមបង្កើតបរិយាកាសអំណោយផលដល់ការឆ្លើយតបក្នុងចំណោមក្រុមប្រឈមមុខ និងការឆ្លើយតបនៅកំរិតឃុំ សង្កាត់។

ភាពយឺតយ៉ាវនៃការផ្តល់ទិន្នន័យឬរបាយការណ៍ មកអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺនៅតែជាបញ្ហាប្រឈមដដែរ ទោះបីជាមានលក្ខណៈប្រសើរជាងមុនក៏ដោយ ជាពិសេសក្នុងចំណោមដៃគូអភិវឌ្ឍ និងវិស័យឯកជន។

៧. អនុសាសន៍

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងស្ថាប័នពាក់ព័ន្ធនានានិងដៃគូរអភិវឌ្ឍរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រជាតិធានាចីរភាព សម្រាប់ឆ្លើយតបការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ជាក់ឱ្យអនុវត្តនិយាមប្រតិបត្តិសម្រាប់ការធ្វើសមាហរណកម្មកម្មវិធីអេដស៍នៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់ ស្របតាមកម្មវិធីកែទម្រង់រៀមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

៣. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបន្តធ្វើផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំស្របតាមអាណត្តិរបស់ខ្លួន និងស្របជាមួយផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ដាក់ក្នុងផែនការថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្តនីមួយៗ និងស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣៖ ការផ្សារភ្ជាប់ថវិកាទៅនឹងការគ្រប់គ្រងគោលនយោបាយ។

៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តនិងពង្រីកវិសាលភាពនៃការផ្តល់ថវិកាគាំទ្រដល់ការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដែលស្នើឡើងដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីមានលទ្ធភាពក្នុងការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត បង្កើនសកម្មភាពអប់រំការបង្ការការឆ្លងមេរោគអេដស៍ ការជួយស្វែងរកករណីអេដស៍ថ្មី ការបញ្ជូនអ្នកផ្ទុកមេរោគអេស៍ទៅទទួលសេវា ថែទាំព្យាបាល ការសម្របសម្រួលបង្កបរិយាកាសអំណោយផលដូចចែងក្នុងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

៦. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងផែនការ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត អង្គការសង្គមស៊ីវិលពាក់ព័ន្ធ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញប្រជាជនក្រុមប្រឈម ត្រូវបន្តសហការរួមគ្នាពង្រីកការផ្តល់ប័ណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ និងប្រជាជនក្រុមប្រឈមតាមរយៈការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

៧. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តជំរុញការប្រយុទ្ធនឹងជំងឺអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាននានា ដោយដាក់ឱ្យអនុវត្តតាមប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.ក ចុះ

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាសគ្រឹះស្ថាន និង ការបង្ការទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ និងប្រកាសលេខ១៩៤ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យនិងសន្តិសុខការងារនៃ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មាន្ត។

៨. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងទំនាក់ ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ត្រូវបន្តជំរុញការ ផ្សព្វផ្សាយនិងអនុវត្តច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និង ជំងឺអេដស៍ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការត្រួតពិនិ ត្យគ្រឿងញៀន និងគោលនយោបាយភូមិឃុំមានសុវត្ថិភាពដល់មហាជនទូទៅ និង អ្នកអនុវត្តច្បាប់។

៩. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវជំរុញការបញ្ចូលសេវាមេរោគអេដស៍ និងជំងឺ អេដស៍ទៅក្នុងមូលនិធិសមធម៌ ដើម្បីអ្នកផ្តល់សេវានៅតាមមូលដ្ឋានសុខាភិបាលបានទទួលការទូទាត់ ថវិការលើសេវាដែលផ្តល់ពីមូលនិធិសមធម៌។

១០. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមគ្នាសិក្សាលទ្ធភាពផ្តល់ការគាំទ្រសេវាគាំទ្រផ្នែកថែទាំ សុខភាពជូនអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

ឯកសារយោង:

១. របាយការណ៍វឌ្ឍនភាព និងសមទិ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ របស់នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ របស់នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៨ របស់នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៨ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើស្បែក និងកាមរោគ។

៦. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងការពារជាតិ។

៧. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងអប់រំយុវជន និងកីឡា។

៨. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៩. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងអភិវឌ្ឍជនបទ។

១០. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

១១. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងផែនការ ។

១២. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន។

១៣. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

១៤. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

១៥. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងបរិស្ថាន។

១៦. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងទេសចរណ៍។
១៧. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
១៨. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងពាណិជ្ជកម្ម។
១៩. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើមឆ្នាំ២០១៨ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។
២០. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងការបរទេស។
២១. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ៥ខែដើម ឆ្នាំ២០១៨ របស់ក្រសួងកិច្ចការនារី។
២២. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អង្គកា UNFPA
២៣. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អង្គការPSI
២៤. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អង្គការ UNAIDS
២៥. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អង្គការ AHF
២៦. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អង្គការ HACC
២៧. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តក្រចេះ
២៨. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកណ្តាល
២៩. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តបាត់ដំបង
៣០. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកែប
៣១. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តពោធិ៍សាត់
៣២. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ
៣៣. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តប៉ៃលិន
៣៤. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តតាកែវ
៣៥. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកំពង់ធំ
៣៦. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកំពត
៣៧. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តរតនៈគិរី

៣៨. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តព្រៃវែង
៣៩. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកំពង់ចាម
៤០. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ
៤១. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ
៤២. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តស្វាយរៀង
៤៣. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង
៤៤. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តសៀមរាប
៤៥. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
៤៦. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ
៤៧. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តមណ្ឌលគិរី
៤៨. ទំរង់ប្រមូលទិន្នន័យត្រីមាសទី១ ឆ្នាំ២០១៨ របស់ មន្ទីរសុខាភិបាលខេត្តកោះកុង

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១: តារាងក្រសួង រាជធានី ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់ទិន្នន័យមកកាន់អគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ

ល.រ	រាជធានី ខេត្ត	ថ្ងៃទទួលរបាយការណ៍ចុងក្រោយ	វិធីសាស្ត្រក្នុងការផ្ញើ
១	ក្រចេះ	២៥/មេសា/១៨	E-Mail
២	កណ្តាល	០២/ឧសភា /១៨	E-Mail
៣	បាត់ដំបង	០៥/ឧសភា /១៨	E-Mail
៤	កែប	០៥/ឧសភា /១៨	E-Mail
៥	ពោធិ៍សាត់	០៨/ឧសភា /១៨	E-Mail
៦	ត្បូងឃ្មុំ	០៩/ឧសភា /១៨	E-Mail
៧	ប៉ៃលិន	០៩/ឧសភា /១៨	E-Mail
៨	តាកែវ	០៩/ឧសភា /១៨	E-Mail
៩	កំពង់ធំ	១០/ឧសភា /១៨	E-Mail
១០	កំពត	១១/ឧសភា /១៨	E-Mail
១១	រតនគិរី	១១/ឧសភា/១៨	E-Mail
១២	ព្រៃវែង	១៦/ឧសភា/១៨	E-Mail
១៣	កំពង់ចាម	១៧/ឧសភា/១៨	E-Mail
១៤	កំពង់ស្ពឺ	១៨/ឧសភា/១៨	E-Mail
១៥	បន្ទាយមានជ័យ	២២/ឧសភា/១៨	E-Mail
១៦	ស្វាយរៀង	២២/ឧសភា/១៨	E-Mail
១៧	កំពង់ឆ្នាំង	២៤/ឧសភា/១៨	E-Mail
១៨	សៀមរាប	២៤/ឧសភា/១៨	E-Mail
១៩	រាជធានីភ្នំពេញ	៣០/ឧសភា/១៨	E-Mail
២០	ឧត្តរមានជ័យ	៣០/ឧសភា/១៨	E-Mail
២១	មណ្ឌលគីរី	៣០/ឧសភា/១៨	E-Mail
២២	កោះកុង	៣០/ឧសភា/១៨	E-Mail

ក្រសួង

១	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	២៥/មេសា /១៨	ឯកសារចម្លង
២	ក្រសួងអប់រំ យុវជន និងកីឡា	១៩/ឧសភា /១៨	E-Mail
៣	ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	៣០/ឧសភា /១៧	ឯកសារចម្លង
៤	ក្រសួងការពារជាតិ	២៣/ឧសភា/១៨	ឯកសារចម្លង
៥	ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	២៣/ឧសភា/១៨	ឯកសារចម្លង
៦	ក្រសួងសាធារណការ និងដឹកជញ្ជូន	២៥/ឧសភា/១៨	E-Mail
៧	ក្រសួងផែនការ	២៥/ឧសភា/១៨	E-Mail
៨	ក្រសួងមហាផ្ទៃ	២៥/ឧសភា/១៨	Phone
៩	មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺអេដស៍សើរស្បែក និងកាមរោគ	២៨/ឧសភា/១៨	E-Mail
១០	ក្រសួងពាណិជ្ជកម្ម	៣០/ឧសភា/១៨	E-Mail
១១	ក្រសួងបរិស្ថាន	៣០/ឧសភា/១៨	E-Mail
១២	ក្រសួងទេសចរណ៍	៣១/ឧសភា/១៨	E-Mail
១៣	ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	៣១/ឧសភា/១៨	E-Mail
១៤	ក្រសួងរ៉ែ និងថាមពល	៣១/ឧសភា/១៨	E-Mail
១៥	ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់	៣១/ឧសភា/១៨	E-Mail
១៦	ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច	៣១/ឧសភា/១៨	E-Mail
១៧	ក្រសួងកិច្ចការនារី	៣១/ឧសភា/១៨	E-Mail
១៨	ក្រសួងអភិវឌ្ឍជនបទ	៣១/ឧសភា/១៨	E-Mail

អង្គការ

១	PSI	២៣/ឧសភា /១៨	E-Mail
២	UNFPA	២៤/ឧសភា /១៨	E-Mail
៣	UNAIDS	២៥/ឧសភា /១៨	E-Mail
៤	AHF	១៥/ឧសភា /១៨	E-Mail
៥	HACC	៣០/ឧសភា /១៧	E-Mail

ឧបសម្ព័ន្ធទី២: របាយការណ៍ចំនួនបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមរាជធានី ខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	៣៣៥	០	0.00
២	កណ្តាល	១១០៩	០	0.00
៣	បាត់ដំបង	២៣០២	០	0.00
៤	កែប	០	០	0.00
៥	ពោធិ៍សាត់	៧៦៩	៧០២	៩១.២៩
៦	ត្បូងឃ្មុំ	៨១៨	៤០៥	៤៩.៥១
៧	ប៉ៃលិន	០	០	0.00
៨	តាកែវ	៨៩៤	០	0.00
៩	កំពង់ធំ	៦១៤	៦១៤	១០០
១០	កំពត	៣៩៩	៣៩៩	១០០
១១	រតនគិរី	០	០	0.00
១២	ព្រៃវែង	៨៩៣	៨៩៣	១០០
១៣	កំពង់ចាម	៧៩៩	៤៥៤	៥៦.៨២
១៤	កំពង់ស្ពឺ	៥៧៥	៥៦២	៩៧.៧៤
១៥	បន្ទាយមានជ័យ	០	០	0.00
១៦	ស្វាយរៀង	៣៧៨៣១៥	៣១៥	៨៣.៣៣
១៧	កំពង់ឆ្នាំង	៥៦៦	៥៦៦	១០០
១៨	សៀមរាប	៣៣២២	៣៣២២	១០០
១៩	រាជធានីភ្នំពេញ	២០១៩៥	១១៩៨	៥.៩៣
២០	ឧត្តរមានជ័យ	០	០	0.00
២១	មណ្ឌលគីរី	០	០	0.00
២២	កោះកុង	៤០៤	០	0.00
	សរុប	៣៤៣៧២	៩៤៣០	២៧.៤៣

ឧបសម្ព័ន្ធទី៣: របាយការណ៍ចំនួនក្រុមបុរសស្រលាញ់បុរស ដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមរាជធានី ខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	០	០	0.00
២	កណ្តាល	៩៤៥	០	0.00
៣	បាត់ដំបង	៣៦៦៥	០	0.00
៤	កែប	០	០	0.00
៥	ពោធិ៍សាត់	១៤៣០	១៤២៤	៩៩.៥៨
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	០	០	០
៩	កំពង់ធំ	៥៧៧	០	០
១០	កំពត	០	០	០
១១	រតនគិរី	០	០	០
១២	ព្រៃវែង	៥៤៥	៥៤៥	១០០
១៣	កំពង់ចាម	០	០	0.00
១៤	កំពង់ស្ពឺ	៥៦៣	៥១២	៩០.៩៤
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	៦៥	០	០
១៧	កំពង់ឆ្នាំង	៥៧៦	០	០
១៨	សៀមរាប	១៦០៦	៣៨៤	២៣.៩១
១៩	រាជធានីភ្នំពេញ	៦២៥៩	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	០	០	០
២២	កោះកុង	០	០	០
	សរុប	១៦២៣១	២៨៦៥	១៧.៦៥

ឧបសម្ព័ន្ធទី៤: របាយការណ៍ចំនួនក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ដែលបានទទួលការអប់រំពីជំងឺអេដស៍ នៅតាម រាជធានី ខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	០	០	០
២	កណ្តាល	១៣១៩	១៣១៩	១០០
៣	បាត់ដំបង	២៦០	០	០
៤	កែប	០	០	០
៥	ពោធិ៍សាត់	៤១៤	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	០	០	០
៩	កំពង់ធំ	៣៨០	០	០
១០	កំពត	៨	០	០
១១	រតនគិរី	០	០	០
១២	ព្រៃវែង	១២០	០	០
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	៦៦៤	៦២៦	៩៤.២៧
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	៨៨	៨៨	១០០
១៨	សៀមរាប	២១៤	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	០	០	០
២២	កោះកុង	០	០	០
	សរុប	៣៤៦៧	២០៣៣	៥៨.៦៣

ឧបសម្ព័ន្ធទី៥: របាយការណ៍ចំនួនកម្មករចល័តក្នុងស្រុក ដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	០	០	០
២	កណ្តាល	១១៥៧៨	០	០
៣	បាត់ដំបង	០	០	០
៤	កែប	០	០	០
៥	ពោធិ៍សាត់	០	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	០	០	០
៩	កំពង់ធំ	០	០	០
១០	កំពត	០	០	០
១១	រតនគិរី	០	០	០
១២	ព្រៃវែង	១៣២៩១១	១៣២៩១១	១០០
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	០	០	០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	០	០	០
១៨	សៀមរាប	០	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	០	០	០
២២	កោះកុង	០	០	០
	សរុប	១៤៤៤៨៩	១៣២៩១១	៩១.៩៨

ឧបសម្ព័ន្ធទី៦: របាយការណ៍ចំនួនក្រុមឯកសណ្ឋាន ដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនក្រុមឯកសណ្ឋាន ដែលបានទទួលការអប់រំ	ចំនួនក្រុមឯក សណ្ឋានគោលដៅ	ភាគរយ
១	ក្រចេះ	០	០	០
២	កណ្តាល	១១៥	២៧៣០	៤.២១
៣	បាត់ដំបង	៥៨០	៣៩៨៥	១៤.៥៥
៤	កែប	០	៥៩៣	០
៥	ពោធិ៍សាត់	០	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	១០២៥	១០២៥	១០០
៩	កំពង់ធំ	៧១៩	២៥៤២	២៨.២៨
១០	កំពត	៦៨០	២២៩០	២៩.៦៩
១១	រតនគិរី	០	០	០
១២	ព្រៃវែង	០	៣២៦៤	០
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	០	០	០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	១៥២៤	១៥៣៤	៩៩.៣៤
១៨	សៀមរាប	០	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	០	៨៨២	០
២២	កោះកុង	១៤៣	២០០	៧១.៥
	សរុប	៤៧៨៦	១៩០៤៥	២៥.១២

ឧបសម្ព័ន្ធទី៧: របាយការណ៍ចំនួនក្រុមយុវវ័យក្នុងសាលាដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមថ្នាក់ក្រោមជាតិ

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	០	០	០
២	កណ្តាល	២៣២០៧៨	៦៨៨៧	២.៩៦
៣	បាត់ដំបង	៣២៨៥៤២	១២៧១៦៩	៣៨.៧
៤	កែប	០	០	០
៥	ពោធិ៍សាត់	១០១៥៧	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	១៦៨០៥២	១៦៨០៥២	១០០
៩	កំពង់ធំ	២៨៦៥៥៤	៨៥៩៦៦	២៩.៩៩
១០	កំពត	២៦៧២០៨	១១១៧៩០	៤១.៨៣
១១	រតនគិរី	០	០	០
១២	ព្រៃវែង	៤៣២៣៤៨	៦០០	០.១៣
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	២៦៣៦៥៨	២៦៣៦៥៨	១០០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	៦៥៤៧៣	៦៥៤៧៣	១០០
១៨	សៀមរាប	០	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	៥១៥៩៥	០	០
២១	មណ្ឌលគីរី	១៧៥៩៧	១៧៥៩៧	១០០
២២	កោះកុង	៣៩៣៣១	៧០១	១.៧៨
	សរុប	២១៦២៥៩៣	៨៤៧៨៩៣	៣៩.២

ឧបសម្ព័ន្ធទី៨: របាយការណ៍ចំនួនក្រុមយុវវ័យក្រៅសាលាដែលបានទទួលការអប់រំពីជំងឺអេដស៍នៅតាមថ្នាក់ក្រោមជាតិ

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	០	០	០
២	កណ្តាល	០	០	០
៣	បាត់ដំបង	០	០	០
៤	កែប	០	០	០
៥	ពោធិ៍សាត់	១៨២៦០១	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	០	០	០
៩	កំពង់ធំ	០	០	០
១០	កំពត	៨៣០	០	០
១១	រតនគិរី	០	០	០
១២	ព្រៃវែង	០	០	០
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	០	០	០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	០	០	០
១៨	សៀមរាប	០	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	០	០	០
២២	កោះកុង	០	០	០
	សរុប	១៨៣៤៣១	០	០

ឧបសម្ព័ន្ធទី៩: របាយការណ៍ចំនួនក្រុមទណ្ឌិត ដែលបានទទួលការអប់រំជំងឺអេដស៍នៅតាមថ្នាក់ក្រោមជាតិ

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	៥៣៧	៥៣៧	១០០
២	កណ្តាល	៣៦៧	៩០	២៤.៥២
៣	បាត់ដំបង	១០៩៩	០	០
៤	កែប	០	០	០
៥	ពោធិ៍សាត់	០	០	០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	៣៨៦	៣៣៥	៨៦.៧៨
៩	កំពង់ធំ	៦៤៧	១៧០	២៦.២៧
១០	កំពត	៨១៤	៨១៤	១០០
១១	រតនគិរី	៦	០	០
១២	ព្រៃវែង	៦៥៩	៧០	១០.៦២
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	៦៦០	៦៦០	១០០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	០	០	០
១៧	កំពង់ឆ្នាំង	៦៥៣	៦៥៣	១០០
១៨	សៀមរាប	២៧៧០	២៨៥	១០.២៨
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	០	០	០
២១	មណ្ឌលគីរី	១៥៩	១៥៩	១០០
២២	កោះកុង	៤៩៤	៤៩៤	១០០
	សរុប	៩២៥១	៤២៦៧	៤៦.១២

ឧបសម្ព័ន្ធទី១០: របាយការណ៍រាជធានី ខេត្តរបស់អតិថិជនមកធ្វើតេស្តឈាមរកមេរោគអេដស៍

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	លទ្ធផល	សមិទ្ធផល (%)
១	ក្រចេះ	៥៨០	១២	២.០៧
២	កណ្តាល	២៣៣៥	៣៦	១.៥៤
៣	បាត់ដំបង	១២៥៩	៨៨	៦.៩៩
៤	កែប	៣៣២	០	០.០០
៥	ពោធិ៍សាត់	១៧៣	៣៧	២១.៣៩
៦	ត្បូងឃ្មុំ	២០៦	២៤	១១.៦៥
៧	ប៉ៃលិន	១១៥	២	១.៧៤
៨	តាកែវ	៧៣០	០	០.០០
៩	កំពង់ធំ	៤៧២	១៩	៤.០៣
១០	កំពត	២០៤	៣៩	១៩.១២
១១	រតនគិរី	៤១៧	១៦	៣.៨៤
១២	ព្រៃវែង	២៦៦	០	០.០០
១៣	កំពង់ចាម	២២១២	០	០.០០
១៤	កំពង់ស្ពឺ	១៧៤៩	១៣	០.៧៤
១៥	បន្ទាយមានជ័យ	៩៧១	៧១	៧.៣១
១៦	ស្វាយរៀង	៥៨៩៤	០	០.០០
១៧	កំពង់ឆ្នាំង	១៦៧	០	០.០០
១៨	សៀមរាប	៨៤០	៩៤	១១.១៩
១៩	រាជធានីភ្នំពេញ	៧៩០៥	៨៤	១.០៦
២០	ឧត្តរមានជ័យ	៨៦	១២	១៣.៩៥
២១	មណ្ឌលគីរី	២០៩	០	០.០០
២២	កោះកុង	២៨៧	២០	៦.៩៧
	សរុប	២៧៤០៩	៥៦៧	២.០៧

ឧបសម្ព័ន្ធទី១១: របាយការណ៍ចំនួនកុមារងាយរងគ្រោះដែលទទួលការគាំទ្រសង្គមទៅតាមរាជធានី ខេត្ត

ល.រ	រាជធានី-ខេត្ត	ចំនួនសរុប	ចំនួនកុមារបានទទួលការគាំទ្រ	សមិទ្ធផល (%)
១	ក្រចេះ	០	០	០
២	កណ្តាល	២១៣	០	០
៣	បាត់ដំបង	០	០	០
៤	កែប	០	០	០
៥	ពោធិ៍សាត់	៦៥	៦៥	១០០
៦	ត្បូងឃ្មុំ	០	០	០
៧	ប៉ៃលិន	០	០	០
៨	តាកែវ	២១៤	០	០
៩	កំពង់ធំ	០	០	០
១០	កំពត	២១២	៧៨	៣៦.៧៩
១១	រតនគិរី	០	០	០
១២	ព្រៃវែង	២៦៦	០	០
១៣	កំពង់ចាម	០	០	០
១៤	កំពង់ស្ពឺ	០	០	០
១៥	បន្ទាយមានជ័យ	០	០	០
១៦	ស្វាយរៀង	២២៤៦	០	០
១៧	កំពង់ឆ្នាំង	១៤៥	០	០
១៨	សៀមរាប	០	០	០
១៩	រាជធានីភ្នំពេញ	០	០	០
២០	ឧត្តរមានជ័យ	៤១៨	០	០
២១	មណ្ឌលគីរី	០	០	០
២២	កោះកុង	២២	២២	១០០
	សរុប	៣៨០១	១៦៥	៤.៣៤